# ខ្មែរប៉ុស្តិ៍ ឆ្នេរខាងកើត

KhmerPost.us
Printing the Cambodian world news!
PHILADELPHIA
NEW JERSEY
LOWELL
VOL. 04 ISSUE 68 SEP. 24th–OCT. 07th, 2010


P.O. Box 24357. Philadelphia, PA 19120. Advertising: 267.253.3947 KhmerPostUSA@gmail.com
P.O. Box 1318. Lowell, MA 01853. Advertising: 978.758.8547. Email: KhmerPostLowell@gmail.com


| មាតិការឿង | ទំព័រ |
|---|---|
| ១- បទសម្ភាសន៍ជាមួយលោក អ៊ូ សុវណ្ណ | ០៣ |
| ២- រំលឹកខួប៤០ឆ្នាំនៃការចូលទីវង្គត់ | ០៤ |
| ៣- ក្តីស្នេហ៍គ្មានទីបញ្ចប់ (ត) | ០៦ |
| ៤- Cambodia Daily និងស្រ្តីខ្មែរដំបូង | ០៨-១៧ |
| ៥- បើកឡានបុកប៉ូលិស | ១៥ |
| ៦- លោកកឹម សុខា ក្នុងសម្ភាធិ | ២០ |

PHILADELPHIA

## តើមានអ្វីប្លែកនៅហ្វីឡាដែលហៀរ

**ដោយ អ៊ុំ ឈឿម**

**I. សមាគមព្រឹទ្ធាចារ្យខ្មែរ-អាមេរិកាំង លោក អ៊ូ កៅ ធ្វើរាត្រីសមោសរ**




បន្ទាប់ពីអសកម្មមួយរយៈក្នុងការបំរើសេវាដល់ពលរដ្ឋខ្មែរ ព្រោះតែវិបត្តិផ្ទៃក្នុង ទើបថ្ងៃទី១៨ ខែកញ្ញាកន្លងមកនេះ សមាគមព្រឹទ្ធាចារ្យខ្មែរ-អាមេរិកាំង ដឹកនាំដោយលោកប្រធាន អ៊ូ កៅ បានប្រារព្ធរាត្រីសមោសរមួយ ដើម្បីប្រមូលថវិកាទៅស្រោចស្រង់ដល់អាយុជីវិតការិយាល័យដែលមានសភាពទ្រុឌទ្រោមស្ទើរប្រើការលែងកើទៅហើយនោះ ។ សមាគមនេះបានគៀងគរភ្ញៀវកិត្តិយសបានជាង២០០នាក់ ដោយក្នុងនោះគេសង្កេតឃើញមានភ្ញៀវជាតិ និងបរទេសមកជាងច្រើនក្រុម និងច្រើនគណបក្ស ។ ព្រឹទ្ធាចារ្យម្នាក់ ដែលជាសមាជិកសមាគមនេះ បានបញ្ជាក់ថា "ទោះបីពេលនេះមានសញ្ញាល្អសម្រាប់សមាគមក៏ដោយ ក៏រឿងជាអាថិកំបាំងផ្ទៃក្នុងជាទំនាស់ផ្លូវច្បាប់នៅពុំទាន់ជ្រះស្រឡះនៅឡើយទេ ។

**II. សហព័ន្ធខ្មែរកម្ពុជាក្រោមធ្វើបុណ្យបង្សុកូល**

វត្តព្រះពុទ្ធវង្សី ដែលអ្នកខ្លះហៅថា "វត្តកម្ពុជាក្រោម" ស្ថិតនៅលើផ្លូវ Rising Sun Ave. នៅហ្វីឡាខាងជើង បានរៀបចំពីបង្សុកូលមួយក្រោមការផ្តួចផ្តើមរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំតំបន់ញូជឺស៊ី ដឹកនាំដោយលោក ត្រឹង ម៉ានរិទ្ធ និងលោកស្រី សឺន សុផានិតនាថ្ងៃទី១១ ខែកញ្ញាកន្លងមកនេះ ។ នេះជាពិធីបុណ្យបង្សុកូលដល់វិញ្ញាណក្ខន្ធយុវជនខ្មែរក្រោម មានឈ្មោះ ចៅ ណែត ដែលត្រូវបានយុទ្ធជនយួនមួយក្រុមកាប់សម្លាប់យ៉ាងសាហាវព្រៃផ្សៃ ។

**សេចក្តីអំពាវនាវរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ស្តីពីសោកនាកម្មខ្មែរក្រោម**

សហព័ន្ធខ្មែរកម្ពុជាក្រោម សូមប្រគេន និងជំរាបដល់ជនរួមឈាមខ្មែរក្រោម ខ្មែរក្នុងស្រុកព្រះរាជាណាចក្រកម្ពុជា និងប្រទេសទីពាជុំវិញសកលលោក ជាទីគោរពរាប់អាន ។ សោកនាកម្ម ការឈឺចាប់ មានឃាតកម្មពីគ្រប់រូបទាំងអស់មកលើខ្មែរក្រោម ទាំងអ្នកដឹកនាំ ក៏ដូចជាជនជាតិយួនប្រកាន់ពូជសាសន៍មួយចំនួន។

កាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១០ មានព្រឹត្តិការណ៍យួនកាប់ខ្មែរនៅក្នុងខេត្តរោងដំរី យួនហៅថា តៃនិញ តំបន់ចំការកៅស៊ូរបស់ជនជាតិយួន បណ្តាលឱ្យមានគ្រោះថ្នាក់ដូចខាងក្រោម ដែលយុវជនទាំង ២២នាក់ បានបំរើការងារជាកម្មករនៅទីនោះ។ ជនរងគ្រោះមាននាម ដូចខាងក្រោម :



១- ចៅ ណែត អាយុ២២ឆ្នាំ ត្រូវបានក្រុមយួនកាប់ស្លាប់ រស់នៅភូមិរលាំង ឃុំរលាំង ស្រុកស្វាយទង ខេត្តមាត់ជ្រូក ។

២- ចៅ ផាត រស់នៅឃុំបន្ទាយស្វាយ ស្រុកស្វាយទង ខេត្តមាត់ជ្រូក រងរបួសជាទម្ងន់ ទើបទទួលមរណៈភាពកាលពីថ្ងៃទី៧ កញ្ញា ឆ្នាំ២០១០។

៣- ចៅ កែវ រស់នៅភូមិបន្ទាយស្វាយ ស្រុកស្វាយទង ខេត្តមាត់ជ្រូក រងរបួសជាទម្ងន់ព្យាបាលនៅមន្ទីរពេទ្យ ។

**(តទៅទំព័រទី ២២)**

LOWELL

## វត្តពីរឈ្មោះតែមួយ ត្រៃរតនារាម ឡើងតុលាការ

**ឡូវែល :** នាឱកាសសវនាការរបស់តុលាការថ្នាក់លើនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០នេះ ប្រជាពលរដ្ឋប្រមាណ១០នាក់ ពាក់បដារបង្ហាញពីការមិនពេញចិត្តចំពោះវិវាទរវាងវត្តជាន់លើ និងវត្តជាន់ក្រោម ដែលមានឈ្មោះតែមួយ ត្រៃរតនារាម នៅទីក្រុងឡូវែល ។




ឆេង វ៉ែន : គេមកនេះមិនមករកឈ្នះ ឬចាញ់ដែរ គឺផ្សះផ្សាគ្នា នោះត្រូវឈប់ទាំងអស់គ្នាទាំងម្តង (សួរ : បើឈប់ទាំងអស់គ្នា មាននរណាគ្រប់គ្រងវត្ត) វត្តនៅមានតែនាំគ្នាបោះឆ្នោតរើសគ្នាតាមប្រជាធិបតេយ្យរកតំណាងទៅ (សួរ : ចុះតុលាការឱ្យរើសតំណាងហើយម៉េចក៏ធ្វើមិនបាន?)

**(តទៅទំព័រទី ១២)**

## ខ្មែរបោះឆ្នោតឱ្យខ្មែរនៅឡូវែល



**ខ្មែរប៉ុស្តិ៍, ឡូវែល :** នាប៉ុន្មានខែចុងក្រោយនេះ សហគមន៍ខ្មែរនៅឡូវែល មានមោទនភាពនឹងឃើញលោក មាស សែម ដើមកំណើតខ្មែរមកឈរឈ្មោះជាបេក្ខជនសមាជិកសភាអាមេរិកាំងនៅតំបន់ ឌីស្រ្ទីក លេខ៥ នៅទីប្រជុំជនឡូវែលតែម្តង ។ "ពាក្យខ្មែរត្រូវជួយខ្មែរ ទៅបោះឆ្នោតឱ្យខ្មែរ" បានឮរន្ទឺពីមាត់មួយទៅមាត់ ហៀរហូរពីឡូវែលទៅតំបន់ជិតខាងយ៉ាងគួរឱ្យចាប់អារម្មណ៍ ។ រីឯលទ្ធផលនៃការបោះឆ្នោតជុំទី១ កាលពីថ្ងៃទី ១៤ ខែកញ្ញា ដែលលោក មាស សែម ប្រកួតនឹងបេក្ខជនគណបក្សសាធារណរដ្ឋដូចគ្នាបីនាក់ទៀត បានផ្តល់ចំណាត់ថ្នាក់លេខពីរជូនលោក មាស សែម ដែលមានសម្លេងឆ្នោត ៦៦២៤ ទល់នឹងជ័យលាភី ចន គលនីក ដែលមានសន្លឹកឆ្នោត៩៤៨៧ សម្លេង ។




**អគ្រេ ជា** បានតាមដានព្រឹត្តិការណ៍នៃការបោះឆ្នោតនៅឡូវែល ជាទីក្រុងដែលសម្បូរទៅដោយអន្តោប្រវេសន៍ក្នុងចំណោមលេខ៤ ហើយផ្តល់បានការវិភាគ និងបទពិសោធន៍ពីព្រឹត្តិការណ៍ដ៏សំខាន់នោះជាភាសាអង់គ្លេស ។ នៅក្នុងអត្ថបទនេះ បងប្អូនខ្មែរគួរចងចាំនូវស្ថិតិមួយចំនួន ដែលមានលក្ខណៈផ្លូវការកាលពីឆ្នាំ២០០០ **(តទៅទំព័រទី១៥)**




# Stop N' Shop Discount Liquor

2305 Admiral Wilson Blvd., Camden, NJ 08105

Phone: (856) 365-4377 Fax: (856) 365-1342

Store Hours : Mon. –Thurs. 9am – 10pm
Fri. – Sat. 9am – Midnight
Sunday Noon – 10p.m
***OPEN 365 DAYS***

## AFTER LABOR DAY SALE!!!



**REMY MARTIN**
V.S.O.P. $35.99 750 ML.
X.O. $99.99 750 ML.






**HENESSY V.O.S.P.**
$39.99
750 ML.



**MARTELL CORDON BLUE**
$93.99
750 ML.






**COURVOISIER XO**
$99.99
750 ML.



**ABSOLUT VOLKA**
$18.09 750 ML.
$29.09 1.75 L.

BEER:

Tsing Tao..............12 Oz. 24 Loose Btls. $23.99
Heineken ..............12 Oz. 24 Loose Btls. $23.99
Corona..................24 Loose Btls. $23.99
"33" Export Vietnam...........................$29.99
Bud...................... 12 Oz. Loose Btls. $15.99
Sapporo..............12 Oz. 24 Loose Btls. $24.99

# បទសម្ភាសន៍ជាមួយលោក អ៊ូ សុវណ្ណ អគ្គកុងស៊ុលកិត្តិយសនៅឡូវែល ម៉ាសាឈូសែត

**ដោយ : ពិន សំខុន**

•••ក្រសួងការបរទេសកម្ពុជាបានបង្កើតការិយាល័យមួយចំនួនដែលស្ថិតនៅក្រោមឱវាទស្ថានទូតខ្មែរប្រចាំសហរដ្ឋអាមេរិក ដែលមានឈ្មោះថា ស្ថានកុងស៊ុលកិត្តិយស ។ នៅទីក្រុងឡូវែល ស្ថានកុងស៊ុលនេះមានកំណើតជាងមួយឆ្នាំហើយ មានទីតាំងនៅលើផ្លូវ CHEMSFORD ។

លោក អ៊ូ សុវណ្ណ បានត្រូវទទួលឋានៈជាអគ្គកុងស៊ុលកិត្តិយសទី១ ប្រចាំទីក្រុងឡូវែលនេះ ។ លោកជាអតីតចាងហ្វាងកាសែតសម្លេងយុទ្ធជនខ្មែរនៅកម្ពុជា និងជាសមាជិកជាន់ខ្ពស់នៃគណបក្សសម រង្ស៊ី ដែលបានផ្ទេរខ្លួនចូលទៅគណបក្សប្រជាជនកាលពីជាង២ឆ្នាំមុន បន្ទាប់ពីបានមករស់នៅទីក្រុងឡូវែលប្រមាណ១០ឆ្នាំហើយ ។ លោក អ៊ូ សុវណ្ណ បានផ្ដល់បទសម្ភាសន៍ដល់ខ្មែរប៉ុស្តិ៍អំពីស្ថានកុងស៊ុលខ្មែរនៅឡូវែលដូចតទៅ :

**ខ្មែរប៉ុស្តិ៍** : តើលោកជាអគ្គកុងស៊ុលទី១ នៅទីនេះឬ?

**អ៊ូ សុវណ្ណ** : តាមពិតទៅមានអគ្គកុងស៊ុលខ្មែរពីររូចទៅហើយ តែនៅតាមតំបន់ផ្សេង ទី១នៅទីក្រុងឡុងប៊ិច កាលីហ្វ័រនា ទី២នៅទីក្រុងស៊ីអាតុល រដ្ឋវ៉ាស៊ីនតុន ឯខ្ញុំនេះជាលំដាប់ទី៣នៅសហរដ្ឋអាមេរិក ហើយជាអគ្គកុងស៊ុលដំបូងនៅញូអិនគ្លិននេះ ហើយនៅថ្ងៃមុខនឹងបង្កើតស្ថានកុងស៊ុលមួយទៀត នៅហ្វីឡាដែលហ្វៀ រដ្ឋផែនស៊ីវេនា ដែលមានលោក សុខ សារឿន ជាអគ្គកុងស៊ុល និងលោក គីម សុភក្រ្ត ជាអគ្គកុងស៊ុលរង។ នៅឡុងប៊ិចដំណើរការណ៍ស្ថានកុងស៊ុលនៅទីនោះបានត្រូវផ្អាកដោយបញ្ហាបច្ចេក-ទេស ឥឡូវនេះកំពុងរកលទ្ធភាពបើកមកវិញ ។

**ខ្មែរប៉ុស្តិ៍** : ហេតុអ្វីកម្ពុជាត្រូវការមានស្ថានកុង-ស៊ុលច្រើននៅសហរដ្ឋអាមេរិកនេះ?





**អ៊ូ សុវណ្ណ** : បាទ! យោងតាមសន្ធិសញ្ញានៅទីក្រុងវីយែន ស្ដីអំពីទំនាក់ទំនងកុងស៊ុលជាលក្ខណៈអន្តរជាតិ ឆ្នាំ១៩៦៣នោះ អគ្គកុងស៊ុលតំណាងការទូតដែរ តែមិនពេញលក្ខណៈ គឺជួយរំលែកការងារស្ថានទូតនៅក្នុងតំបន់ដែលខ្លួនទទួលខុសត្រូវ រីឯស្ថានទូតវិញ ទទួលខុសត្រូវជាមួយរដ្ឋាភិបាលសហ-ព័ន្ធទាំងមូល។ ដោយសារតែសហរដ្ឋអាមេរិកនេះជាប្រទេសធំ ចម្ងាយផ្លូវក៏ឆ្ងាយ ទើបអគ្គកុងស៊ុលកិត្តិយសនេះត្រូវបង្កើតឡើងដើម្បីជួយវិស័យទំនាក់ទំនងនៅតាមតំបន់ជូនស្ថានទូតខ្មែរ នៅញូអិនគ្លិននេះខ្ញុំមានភារៈទទួលខុសត្រូវលើ៥-៦រដ្ឋ ដែលត្រូវទាក់ទងជាមួយរដ្ឋ និងអាជ្ញាធរមូលដ្ឋានរបស់គេ ដូចជា រដ្ឋមេន, ញូហមស្ពៀ, កណិចទីកិត, រដ្ឋម៉ា-សាឈូសែត, រដ្ឋរ៉ូដអាយឡិន, រដ្ឋញូយ៉កខាងជើង ។ ជាទូទៅអ្នកទទួលខុសត្រូវជាអគ្គកុងស៊ុលនេះ ប្រទេសជាច្រើនគេប្រគល់ទៅឱ្យមនុស្សដែលជាម្ចាស់ស្រុក ដូចជាប្រទេសថៃ គេមានអគ្គកុងស៊ុលរបស់គេនៅបុស្តុននេះ គឺជាជនជាតិអាមេរិកាំងតែម្តង ។ ប្រទេសប៉ាគីស្ថាន ក៏ដូចគ្នាដែរ ចំណែកឯខ្មែរយើងនៅជប៉ុនបានជ្រើសយកជនជាតិជប៉ុនជាកុងស៊ុលកិត្តិយស ដោយសារជនជាតិជប៉ុនច្រើនជាអ្នកមាន ជួយយើងខាងមនុស្សធម៌ច្រើន ដូចជាកុមារកំព្រា, ជនពិការ, សង់សាលារៀន, ជីកអណ្ដូងទឹក, ជួយទប់ស្កាត់ជម្ងឺអេដស៍ ។ល។ គឺរដ្ឋបានលើកទឹកចិត្តគេឱ្យប្រមូលអ្នកឯទៀតៗឱ្យចូលមកជួយកម្ពុជា ។ រីឯនៅសហរដ្ឋអាមេរិកនេះ អគ្គកុងស៊ុលកិត្តិយសជាខ្មែរ ពីព្រោះខ្មែរយើងត្រូវការអ្នកស្គាល់ ដឹងអំពីវប្បធម៌ អរិយធម៌ ភូមិសាស្ត្រ សុខទុក្ខជាខ្មែរ នៅក្នុងតំបន់ដែលមានខ្មែរច្រើនរស់នៅ ដើម្បីជាជំនួយដោះស្រាយបញ្ហាលិខិត, បែបបទ, វិសា, អ្វីដែលពួកគាត់ត្រូវការដើម្បីទៅសួរសុខទុក្ខបងប្អូន ឬក្រដាសស្នាមផ្សេងៗ ជួយសំរួលអ្វីដែលអាចធ្វើទៅបាន...។

**ខ្មែរប៉ុស្តិ៍** : ដូច្នោះ តើតួនាទីអគ្គកុងស៊ុលគឺអ្វីខ្លះ?

**អ៊ូ សុវណ្ណ** : តួនាទីខ្ញុំមានបីចំណែក គឺទី១ ទំនាក់ទំនងទៅនឹងរដ្ឋបាល ដូចជាចេញវិសាជូនខ្មែរ-អាមេរិកាំងដែលទៅកម្ពុជា ។ បើទៅយកវិសាស្រុកខ្មែរក៏បានដែរ តែពេលខ្លះមានបញ្ហាមួយ គឺគ្មានវិសាខាងអាមេរិក គេមិនឱ្យឡើងយន្តហោះ, ពន្យាពេលលិខិតឆ្លងដែនរបស់ខ្មែរ ឱ្យបងប្អូនមកលេង, មកស្នាក់នៅ, មកសិក្សា, កាលណាអស់សុពលភាពអាចមកពន្យានៅទីនេះ ។ នៅមានការងារមួយទៀត ដូចជា សំបុត្រកំណើត ដែលអាជ្ញាធរអាមេរិកាំងគេទាមទារ ខ្ញុំអាចពិនិត្យលើឯកសារដែលពួកគាត់មានបកប្រែហើយ "ណូតូរាយ" ជូនឱ្យប្រើប្រាស់ជាផ្លូវការបាន ជូនកាលទៀតដូចជា ខាងអន្តោប្រវេសន៍គេអាចសាកសួរថា អ្នករៀបការតាំងពីមុនឆ្នាំ១៩៧០ ហេតុអ្វីក៏គ្មានលិខិតរៀបការ ខ្ញុំអាចធ្វើលិខិតបញ្ជាក់ជូនប្រើជាផ្លូវការបាន បើទោះជាសាម៉ីខ្លួនបញ្ជាក់ថាជំនាន់ខ្មែរក្រហម ពុំអាចមានលិខិតអ្វីថែរក្សាបានទេ ក៏គេនៅតែត្រូវការលិខិតជាផ្លូវការមួយនោះដែរ ។ ការងារមួយទៀត គឺការពារផលប្រយោជន៍របស់ខ្មែរដែលមករស់នៅទីនេះ ដូចជាបើមានការរើសអើង ការបំរើជំនួសមុខឱ្យរាជរដ្ឋាភិបាលខ្មែរ ដើម្បីផលប្រយោជន៍ខ្មែរទាំងមូល គឺទៅសួរនាំ ទៅដោះស្រាយដែលជាកិច្ចការងារក្នុងការិយាល័យ ។ ទី២ ការងារក្រៅការិយាល័យ គឺជាកិច្ចការសំខាន់មួយទៀតដែរ ដែលត្រូវធ្វើកិច្ចទំនាក់ទំនងជាផ្លូវការរដ្ឋ រកផលប្រយោជន៍ឱ្យខ្មែរ មានពាណិជ្ជកម្ម, សិក្សាធិការ

(តទៅទំព័រទី ១០)


# ការិយាល័យច្បាប់
# មេធាវី ឡូវីស ស. ហាស្កល

Law Office of
Louis S. Haskell

ការិយាល័យយើងខ្ញុំមានការពារក្ដីដោយទទួលបាន
ជោគជ័យតាំងពីឆ្នាំ ១៩៨៨
Excellent Service Since 1988

Areas of Practice: ការិយាល័យច្បាប់យើងមានទទួលធ្វើ

- Automobile Accidents — គ្រោះថ្នាក់ចរាចរណ៍
- Bankruptcy — ក្ស័យធន (បែងក្រុបស៊ី)
- Immigration — អន្តោប្រវេសន៍
- Dog Bites — ឆ្កែខាំ
- Wrongful Death — ស្លាប់ដោយសារអ្នកដទៃ
- Fire and Burn Cases — គ្រោះថ្នាក់ភ្លើងឆេះរលាក



មានបុគ្គលិកនិយាយ
ភាសាខ្មែរ
16 Pine Street, Lowell,
MA 01851
Call: 978-459-8359

# រំលឹកខួប៤០ឆ្នាំនៃការចូលទីវង្គត់របស់អ្នកប្រាជ្ញខ្មែរ

**ដោយ : អ៊ុម លឿម**

គប់ពាលរែងពាលទៅរកខុស គប់ប្រាជ្ញស្រីប្រុសរែងបានត្រូវ គប់មិត្តអបល័ក្សណ៍រែងអាស្រូវ ខុសត្រូវមានព្រោះការសេពគប់ ។

នេះជាពាក្យកាព្យដែលជាស្នាព្រះហស្តរបស់សម្តេចសង្ឃ ព្រះមហាសុមេធាធិបតី ជួន ណាត ជាអ្នកប្រាជ្ញរបស់ជាតិខ្មែរតែមួយអង្គ ដែលមានភាពស្ទាត់ជំនាញខាងផ្លូវព្រះពុទ្ធសាសនា និងទាំងខាងអក្សរសាស្ត្រ ។ ថ្វីត្បិតរហូតមកដល់ពេលនេះ លោកបានទទួលអនិច្ចកម្មអស់ពេល៤០ឆ្នាំទៅហើយក្តី តែកេរ្តិ៍ឈ្មោះរបស់លោកនៅតែស្ថិតនៅក្នុងក្រអៅបេះដូងកុលបុត្រខ្មែរគ្រប់វ័យគ្រប់ជំនាន់ ។

ទោះបីសម្តេចសង្ឃបានសោយទីវង្គត់បានបួនទសវត្សរ៍ហើយក្តី តែព្រះអង្គបានបន្សល់ទុកនូវមរតកសំខាន់ៗជាច្រើន ដែលមរតកទាំងនោះសុទ្ធសឹងជាប្រយោជន៍ដ៏មហាសាលសម្រាប់វប្បធម៌ជាតិ, សម្រាប់ព្រះពុទ្ធសាសនា, សម្រាប់ប្រជាជាតិកម្ពុជា ហើយក្នុងនោះក៏ថែមទាំងជាឱវាទដ៏មានខ្លឹមសារសម្រាប់ដាស់តឿនដល់ជនានុជនជំនាន់ក្រោយៗ ។

ដោយគុណធម៌ដ៏ជ្រាលជ្រៅចំពោះតម្លៃនៃវប្បធម៌ អក្សរសាស្ត្រជាតិ, សាសនា... នេះទើបកេរ្តិ៍ឈ្មោះព្រះអង្គនៅតែក្រអូបហាក់ដូចផ្កាឈូកដុះចេញពីល្បប់ភក់យ៉ាងដូច្នោះដែរ ។ ក្នុងខួបគំរប់៤០ឆ្នាំនៃការបាត់បង់គ្រាប់ពេជ្ររបស់ជាតិខ្មែរនេះ "ខ្មែរប៉ុស្តិ៍" បានព្យាយាមជីកកកាយក្នុងការស្រាវជ្រាវ និងចងក្រងនូវឯកសារនានា ដែលទាក់ទងនឹងព្រះជីវប្រវត្តិរបស់សម្តេច ដើម្បីជាការចែករំលែកដល់ខេមរជាតិរួមលោហិតឱ្យបានជ្រាបអំពីប្រវត្តិរបស់បិតាអក្សរសាស្ត្រនៃយើង ។

**ខាងក្រោមនេះជាជីវប្រវត្តិសម្តេចព្រះសុមេធាធិបតី ជួន ណាត** : កុមារ ជួន ណាត បានចាប់បដិសន្ធិនៅលើមហាចក្រវាឡដ៏ស្រស់ថ្លានេះ នៅថ្ងៃអង្គារ ទី១១ ខែមីនា ឆ្នាំ១៨៨៣ នៅចុងកាត់មាត់ញូកជនបទដាច់ស្រយាលពីទីប្រជុំជនមួយនាភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជាខេត្តពោរពេញទៅដោយតាលព្រឹក្ស ។

លោកតាជួន និងលោកយាយ យូក គឺជាអ្នកផ្តល់កំណើតដល់បុត្រាដែលប្រកបដោយគន្លងធម៌ចំនួនពីរដួង គឺសម្តេចសង្ឃ ជួន ណាត នេះតែម្តង និងកុមារ ជួន នុត ដែលក្រោយមកកុមារក្នុងអំបូរណ៍ដ៏ថ្លៃថ្នូរមួយនេះបានក្លាយជា "ឧកញ៉ាសោភ័ណ្ឌមន្ត្រី ជួន នុត" ។ ក្នុងវ័យ១៤ឆ្នាំ កុមារ ជួន ណាត ពុំបានគិតដល់វ័យឡើងខ្លួនរបស់កុមារឡើយ តែបែរជាសង្វាត់រៀនសូត្រអក្សរសាស្ត្រ និងគណិតសាស្ត្រ ហើយបានបោះបង់ភាពជាគ្រហស្ថ ដើម្បីបំពេញផ្នួសបួសជាសាមណេរ នៅក្នុងថ្ងៃ១៥កើត ខែពិសាខ ស័រិទ្ធិសក្តិ ព.ស ២៤៤១ (ឧសភា ១៨៩៧) នាវត្តពោធិព្រឹក្ស ហៅវត្ត "ពោល្យំ" នៅឃុំរលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ជីវិតជាបព្វជិតបានញ៉ាំងឱ្យសាមណេរ ជួន ណាត មានមោទនភាពពេកណាស់ ហើយនៅឆ្នាំ១៨៩៩ សាមណេរអង្គនេះបានចូលសិក្សាព្រះបរិយត្តិធម៌នៅវត្តឧណ្ណាឡោម ដែលជាវត្តដ៏ល្បីល្បាញមួយនាទីក្រុងភ្នំពេញ ។

ក្នុងវ័យ២១ឆ្នាំ ដែលយុទ្ធជនគ្រប់ៗរូបត្រេកត្រអាលនឹងវ័យរបស់ខ្លួន ដោយការតុបតែងខ្លួនប្រាណ



ជាមួយនឹងសម្លៀកបំពាក់ស្រស់ស្អាតនោះ ប៉ុន្តែសម្រាប់បព្វជិត ជួន ណាត នៅតែរក្សាគ្រងចីវរពណ៌លឿងជំនួសឱ្យសម្លៀកបំពាក់ទាន់សម័យដែលយុវវ័យស្ថិតក្នុងវ័យជាង២០ឆ្នាំ កំពុងតែត្រេកត្រអាល ។ ក្នុងវ័យនេះបព្វជិតដែលពោរពេញដោយវិរិយភាពបានបំពេញឧបសម្បទាជាភិក្ខុនៅខែមិថុនា ឆ្នាំ១៩០៤ នៅវត្តពោធិព្រឹក្ស ដែលជាវត្តដើម ដែលមានព្រះតេជគុណ ម៉ា កេត សុវណ្ណប្បញ្ញោ ជាឧបជ្ឈាយ៍, ព្រះតេជគុណ កែ ម៉ម មិស្សនាគោ ជាគ្រូសូត្រធម្មវាចាចារ្យ និងព្រះតេជគុណ អ៊ុន ខឹម តិក្ខប្បញ្ញោ ជាគ្រូអនុស្សាវនាចារ្យ ។

លុះអំណះតមកភិក្ខុ ជួន ណាត ត្រូវបានទទួលនាមប្បញ្ញត្តិថា "ជោតញ្ញាណោ" ។ ហើយបាននិមន្តត្រឡប់ទៅគង់នៅវត្តឧណ្ណាលោមវិញ បន្ទាប់ពីបានបំពេញជាភិក្ខុហើយនោះ ។

**ចំណេះវិជ្ជា និងកិច្ចការដែលទ្រង់បំពេញបានក្នុងវិស័យព្រះពុទ្ធសាសនា**

ភាសាបរទេសដូចជា លង្កា, ភូមា, ម៉ន, សៀម, លាវ... ពុំមែនជាឧបសគ្គក្នុងការនិយាយប្រាស្រ័យទាក់ទងរបស់សម្តេចឡើយ ។ ក្រៅពីនោះភាសាបារាំងសេស, ភាសាយួន, ភាសាអង់គ្លេសក៏អាចសមល្មមក្នុងការប្រាស្រ័យទាក់ទងបានដែរ ។ កាលនៅជាព្រះគ្រូសង្ឃសត្ថា សម្តេចបានទៅបំពេញវិជ្ជាខាងភាសាសំស្ក្រឹត និងអក្សរសិលាចារិកនៅឯសាលាបារាំងចុងបូព៌ា នាទីក្រុងហាណូយ ប្រទេសយួនខាងជើង ក្នុងសំណាក់លោក លី ហ្វី ណូត ជនជាតិបារាំងជាចាងហ្វាងសាលានេះតែម្តង ក្នុងអំឡុងឆ្នាំ១៩២២ ដល់១៩២៣ ។

ឆ្នាំ១៩១៣ សម្តេចទ្រង់បានចូលប្រឡងដេញប្រយោគក្នុងព្រះឧបោសថរតនារាម (វិហារព្រះកែវមរកត) ចំពោះព្រះភ័ក្ត្រព្រះករុណា សម្តេចព្រះស៊ីសុវត្ថិ បាន៤ប្រយោគ ដែលជាប្រយោគជាន់ខ្ពស់បំផុតនាគ្រានោះ ។ ឆ្នាំ១៩១៥ ទ្រង់បានប្រឡងជាប់លេខ២ ហើយបានទទួលការតែងតាំងជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ ដែលបច្ចុប្បន្នមានឈ្មោះថា "ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត" ។ ឆ្នាំ១៩៤៩ ទ្រង់បានធ្វើជាសមាជិកនៃក្រុមជំនុំតែងវចនានុក្រមខ្មែរ ដែលទ្រង់ ជាលេខាកាន់កិច្ចការនេះលុះចប់ចុងចប់ដើម ។ ឆ្នាំ១៩២៥ ទ្រង់ធ្វើជាសមាជិកនៃក្រុមជំនុំពិនិត្យសេចក្តីខុសត្រូវនៃសៀវភៅនានាដែលសាលាបាលីជាន់ខ្ពស់បានបោះពុម្ពផ្សាយ ។ ឆ្នាំ១៩២៦ សម្តេចត្រូវបានតែងតាំងជាមេប្រយោគក្នុងការប្រឡងយកវិញ្ញាបនប័ត្របឋមសិក្សាខ្មែរ និងការប្រឡងយកសញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់បារាំង-ខ្មែរ នាទីក្រុងភ្នំពេញ ។ (តទៅទំព័រទី ០៥)

Yes you can!

... get free or low-cost health insurance for your children.

- Did you lose your health insurance when you lost your job?
- Do your children have no health insurance?
- Do you wonder how you'll afford your kids' next doctor visit?

AmeriChoice
A UnitedHealth Group Company

(215) 360-9841
Leap Thach

Your children deserve to be healthy.
AmeriChoice can help.



ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)

Nam Vang Restaurant

571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market) (215) 742-9488
Open 7 days a week from 9 a.m. – 9 p.m.

បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច

១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ទាំង ឆារសាច់គោ
- មីកន្ទាំងឆារគ្រឿងសមុទ្រ
- បាយឆារគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:
- នំបញ្ចុកទឹកត្រីពិសេស
- នំបុ័ងបាតេ ឬសាច់គោអាំង
- ខគោ នំបុ័ង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់រស់ជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវ៉ូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ




**ដោយ : គីម ភឿន** ***(តពីលេខមុន)***

•••នាយច្រកសម្លឹងមុខវីរៈដោយងឿងឆ្ងល់ : "លក្ខណ៍អីបង?" ។ វីរៈឆ្លើយសំនួរប្អូនដោយអាណិតៈ

- អូនច្រក! សុំចូលធ្វើទាហានគ្មានការលំបាកអីទេ សុំភ្លាមបានចូលធ្វើភ្លាម ។ ជាតិកំពុងត្រូវការ ។ តែប្អូនត្រូវគិតដល់ផលប្រយោជន៍ និងអនាគតរបស់ប្អូនផង មិនមែនចូលធ្វើទាហានមកពីការក្តៅក្រហាយអស់សង្ឃឹមរឿងអ្វីមួយក៏រត់ចូលធ្វើទាហានតែម្តងទេ ។ អូនត្រូវដឹងថាជាទាហានកាន់អាវុធច្បាំងការពារមាតុភូមិជាអំពើខ្ពង់ខ្ពស់ថ្លៃថ្លាណាស់ តែក្នុងករណីកិច្ចថ្លៃថ្លាខ្ពង់ខ្ពស់នេះមានការឈឺចាប់ និងសោកស្តាយយ៉ាងច្រើនបណ្តាលមកពីភាពអយុតិធម៌ ពីការលំអៀងពីថ្នាក់លើ ។ បងចង់ឱ្យប្អូនយល់ថានៅពីថ្នាក់លើចុះមកក្រោមក្នុងជួរកងទ័ពពីពួកពាក់ផ្កាយចុះមកដល់ពួកស័ក្តិពាក់ពេញស្មាដល់កន្លះស្មារហូតដល់ពួកលោកពាក់តែមួយជាន់ក្រង៉ុកលើស្មា... ទាំងអស់នេះមានមួយចំនួនតិចណាស់ដែលយល់ច្បាស់ពីភារៈកិច្ចបំរើជាតិ មួយចំនួនធំគាត់គិតតែប្រយោជន៍ផ្ទាល់ខ្លួន យកមុខងារបុណ្យស័ក្តិរបស់គាត់បំរើផលប្រយោជន៍សម្រាប់តែខ្លួនគាត់តែប៉ុណ្ណោះ ហើយបង្កភាពអយុត្តិធមិលើកូនចៅថ្នាក់ក្រោមដូចកូនឈ្នួលដាច់ថ្លៃរបស់ខ្លួន មិនមែនទុកឱ្យកូនចៅក្រោមបញ្ជារបស់ខ្លួនបានបំរើជាតិត្រឹមត្រូវទេ បែរជាឱ្យគ្នាធ្វើការបំរើបុគ្គលឯកជនទៅវិញ ។ បងចង់ឱ្យប្អូនបានចូលធ្វើជានាយទាហានដើម្បីឱ្យប្អូនកសាងខ្លួនជាមេដឹកនាំគេ ។ ប្រទេសយើងខ្វះនាយទាហានជាមេដឹកនាំត្រឹមត្រូវមានវិជ្ជាជីវសម្រាប់បេសកកម្មដ៏ឧត្តមនេះ ។ យើងមាននាយទាហានសន្ទឹកសន្ទាប់ដែរតែភាគច្រើនៗតែនាយទាហានសម្រាប់ស៊ីផឹកហឺហាស្រោចស្រាលើក្បាលគ្នា អួតអាង បញ្ជាឱ្យកងទ័ពទៅស្លាប់ដូចគេហាលដោយគ្មានចេះស្តាយស្រណោះ ហើយហ៊ានលក់ក្បាលឱ្យសត្រូវដោយងាយបំផុត ដោយគ្មានស្តាយស្រណោះជាតិ ឬកូនចៅក្រោមបញ្ជាដ៏តិចតួចឡើយ... អាណាស្លាប់ក៏ស្លាប់ចុះ ឱ្យតែអញបានរួចខ្លួន ។ មេយើងសព្វថ្ងៃច្រើនតែធុននឹង ។ មានមេល្អត្រឹមត្រូវមួយចំនួនតែមិនចេះអែបអប បុណ្យសក្តិនៅនឹងថ្កល់ គ្មានបានកាន់ការអ្វីសំខាន់ធំដុំនឹងគេ គ្មានបានជួយដល់ជាតិ ឬការពារអំពើអយុត្តិធមិចំពោះថ្នាក់ក្រោមបានជាដុំកំភួនឡើយ ។ ពេលវីរៈនៅស្ងៀមក្នុងសភាពត្រិះរិះ នាយច្រកក៏សួរតបវិញដោយរួសរាន់ :

- ប្រាកដជាខ្ញុំចង់បានក្លាយជាមេដឹកនាំដ៏ល្អសម្រាប់កងទ័ពជាតិយើង តើខ្ញុំត្រូវបំពេញលក្ខណ្ឌអ្វីខ្លះ?

- ប្អូនត្រូវចូលសាលានាយទាហានដើម្បីហ្វឹកហាត់ឱ្យក្លាយជានាយទាហាននៃកងទ័ពជាតិ ។ ដើម្បីបានចូលសាលាយោធាជាន់ខ្ពស់នេះប្អូនត្រូវមានបាក់ឌុបទើបគេទទួល ។ ហេតុនេះលក្ខណ្ឌដែលបងបង្ខំឱ្យអូនបំពេញ គឺត្រឡប់ទៅសាលារៀនវិញ ហើយខំប្រឡងឱ្យជាប់ក្នុងសម័យប្រឡងដែលនៅប៉ុន្មានអាទិត្យខាងមុខនេះ ។ សញ្ញាប័ត្រដែលប្អូនខំប្រឡងយកនេះនឹងជួយប្អូនច្រើនណាស់ ។ បើប្អូនគ្មានសញ្ញាប័ត្រនេះប្អូនត្រូវសុំចូលរៀនសាលាយោធាជាន់ទាប ចេញមកវិញប្អូនបានត្រាន់បើតែជាងពលទោបន្តិចទេ ប្អូនចង់ជួយជាតិ ឬជួយការពារអំពើអយុត្តិធមិចំពោះមិត្តភក្តិក៏មិនអាចជួយបាន ។ ជួយតែខ្លួនឯងមិនទាំងរួចផង ធ្វើម្តេចនឹងជួយអ្នកដទៃ? ហើយខំច្បាំងអស់មួយជីវិតសឹងតែគ្មានសំណាងបានឡើងទៅពាក់ដល់ស័ក្តិមួយផង អនុសេនីយ៍ត្រី) ។ បើប្អូនបានរៀនចេញពីសាលាយោធាជាន់ខ្ពស់ភ្លាម ប្អូនបានជាអនុសេនីយ៍ត្រីភ្លាមហើយបុណ្យស័ក្តិនឹងឡើងតាមឆ្នាំ និងថ្វីដៃបំរើការងារជាស្វ័យប្រវត្តិ ។ ប្អូនអាចមានសំណាងឡើងដល់ថ្នាក់ឧត្តមសេនីយ៍នៅក្នុងវ័យក្មេងក៏អាចថាបាន ។ ពេលនោះទើបប្អូនមានសម្លេងក្នុងការបំរើជាតិ ឬជួយការពារកែប្រែអំពើអយុត្តិធមិនៅក្នុងជួរកងទ័ពបានខ្លះ ។ មានអំពើអយុត្តិធមិច្រើនណាស់ក្នុងជួរកងទ័ពជាតិយើង តែគ្មានលោកណាចង់ជួយកែលំអឡើយ ព្រោះតែផលប្រយោជន៍របស់បុគ្គល ឬរបស់ក្រុមបក្សពួក ។ ឯអ្នករងអំពើអយុត្តិធមិ និងការឈឺចាប់ទាំងប៉ុន្មានគឺពួកពលទាហានថ្នាក់ក្រោម ។ គ្នាពុំមានទីពឹងសោះឡើយ ។ បើប្អូនមានឋានៈជាអនុ-សេនីយ៍ត្រី ប្អូនក៏មានលទ្ធភាពជួយការពារកូនចៅក្រោមបញ្ជារបស់ខ្លួនជាបណ្តើរៗបានដែរ ហើយពួកអ្នកទាំងនេះ នឹងហ៊ានស៊ូស្លាប់រស់ដើម្បីចៅហ្វាយនាយខ្លួនក្នុងសមរភូមិ ។ ពលទាហានយើងពិតជាក្លាហានប្រសិនបើមេដឹកនាំមានយុត្តិធមិ និងក្លាហានគ្រប់គ្រាន់ជាគំរូ ។ បងនិយាយទាំងប៉ុន្មាននេះចង់បង្ហាញឱ្យប្អូនឃើញថា បើប្អូនខំយកសញ្ញាប័ត្របាក់ឌុបនេះបាន អូនអាចក្លាយជានាយទាហានមានលទ្ធភាពច្រើនក្នុងការបំរើជាតិ និងជួយដោះស្រាយវិបត្តិក្នុងកងទ័ពជាតិយើងក្នុងអនាគត តើប្អូនយល់យ៉ាងម៉េចដែរ? ។ នាយច្រកឆ្លើតបវិញដោយគ្មានស្ទាក់ស្ទើរ :

.- ខ្ញុំធ្លាប់តែស្តាប់បង្គាប់បងបុប្ផ តែឥឡូវអស់ពីគាត់ទៅ ខ្ញុំសុំជឿតាមបង ខ្ញុំនឹងខំប្រឡងយកសញ្ញាប័ត្រនោះឱ្យបាន ។ វីរៈញញឹមសម្លឹងនាយច្រកដោយពេញចិត្ត :

-ល្អណាស់ច្រក ។ ប្អូនមិនបានប្រាប់បងថាហេតុអីបានជាអង្គការលើខ្មែរក្រហមសម្លាប់បងបុប្ផឯង?

- រឿងនេះវាបណ្តាលមកពីសិស្សម្នាក់ឈ្មោះបូរី រៀននៅថ្នាក់ទី១១ គ វាជាភ្នាក់ងារខ្មែរក្រហមបង្កប់នៅក្នុងវិទ្យាល័យអង្គតាសោម មានមុខងារជាអ្នកបញ្ចុះបញ្ចូលសិស្សឯទៀតរត់ចូលព្រៃទៅបំរើខ្មែរក្រហម ឯបងបុប្ផជាគ្រូដែលបានជ្រើសតាំងឱ្យនៅក្នុងគណៈកម្មាការវិន័យ និងសីលធមិ ។ គាត់មានភារកិច្ចណែនាំសិស្សឈ្មោះបូរីនេះ ។

**(សុំរង់ចាំអានបន្តទៅទៀតនៅលេខក្រោយទៀត)**


# ចូរធ្វើចលនា!



មួយភាគបីនៃក្មេងៗ ប្រឈមមុខចំពោះបញ្ហាសុខភាពធ្ងន់ធ្ងរខ្លាំងណាស់ ដោយព្រោះតែធាត់ពេក ។ យើងអាចជួយកូនរបស់អ្នកឲ្យជៀសវៀង ជាមួយនឹង :

- ការចូលជាសមាជិកនៅមណ្ឌលហាត់ប្រាណ
- អត្ថប្រយោជន៍ Weight Watchers® របស់យើង (សំរាប់ក្មេងៗ អាយុ 10+)
- ការប្រឹក្សាខាងអាហារមានជីវជាតិ

CHIP បាននាំមកជូនអ្នកដោយ KidzPartners មានផ្តល់ការធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ ឬថោកថ្លៃ សំរាប់ក្មេងៗ និងក្មេង ជំទង់ៗ ដែលគ្មានការធានារ៉ាប់រង ។ ថែមទាំងអត្ថប្រយោជន៍ដែល អាចនាំឲ្យមានសុខភាពល្អអស់មួយជីវិត ។

## ចូរដាក់ពាក្យសុំនៅថ្ងៃនេះ!
## 1-888-888-1211
TTY 1-877-454-8477

Pennsylvania's Children's Health Insurance Program
យើងរ៉ាប់រងក្មេងៗទាំងអស់។

www.chipcoverspakids.com

KidzPARTNERS
ផែនការសំរាប់ក្មេងៗរបស់ HEALTH PARTNERS

www.kidzpartners.com

# A.B.C MONEY TRANSACTION, INC

# $ ក្រុមហ៊ុនផ្ញើប្រាក់ A.B.C

## តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ



| | | ភ្នំពេញ | តាមខេត្ត |
|---|---|---|---|
| ផ្ញើ $100 | យកកម្រៃ | $4.50 | $5.50 |
| $200 | យកកម្រៃ | $9.00 | $11.00 |
| $300 | យកកម្រៃ | $13.50 | $16.50 |
| $500 | យកកម្រៃ | $16.00 | $17.00 |
| $1000 | យកកម្រៃ | $25.00 | $26.00 |
| $1500 | យកកម្រៃ | $35.00 | $36.00 |
| $2000 | យកកម្រៃ | $42.00 | $43.00 |
| $2200 | យកកម្រៃ | $46.00 | $47.00 |

សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

### នៅរដ្ឋ VIRGINIA សូមទាក់ទង

ABC MONEY TRANSATION ,INC.

8 locations to serve you in Virginia

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

**ARIZONA**

◆4215 N 19th Ave. . Tel : 602.266.6744

**GEOERGIA**

◆ 4897 Buford Hwy. Ste. 202. Tel: 770.457.7888

**ILLINOIS**

◆ 4871 N. Broadway . Tel :773.989.7332

**MASSACHUSETTE**

◆ 996 Dorchester Ave. Tel:617.825.9380

◆ 1365-1377 Dorchester Ave. -Ste.4,Froor 1 . Tel : 617.265.4600

**MINNESOTA**

◆ 2718 Nicollet Ave . S.- Ste. 102 B

◆ Tel : 612.871.4731

◆ 6350 Brooklyn Blvd . Tel : 763.503.3947

**NORTH CAROLINA**

◆ 3000 Central Ave. Ste . #9 . Tel : 704-532-4420

**OREGON**

◆6908 N.E. Sandy Blvd . Tel : 503.281.8088

**PHILADFELPHIA**

◆5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794

◆571 Adams Ave . Ave.#4 . Tel : 215.342.6623

**TEXAS**

◆1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461

◆2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817

◆5302 E . Belknap St.- Ste.D6 . Tel : 817.831.4836

◆3538 W . Walnut St. Tel : 972.272.2253

◆11205 Bellaire Blvd . Tel : 281.561.6600

◆10909 Scarsdale Blvd . Tel : 281.481.2700

◆13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

**WASHINTON STATE**

◆766 S.38th St,. Tel : 253.475.2847

◆3818 S.Graham St.-Ste. C Tel : 206.721.2070

Office : 714-590-8740 Fax : 714-590-8776

Cell: 714-603-3509 Toll Free : 1-877-939-0110

## ក្រុមហ៊ុនទទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

### ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្ទាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ ( NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS ) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័ត៌មានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com

# អាថ៌កំបាំង និងសិល្បៈនៃជីវិត
# SECRET AND ART OF LIVING



(តមកពីលេខមុន)

**រៀបរៀងដោយ**
**លោក ម៉ៅ ច័ន្ទសំណុំ**

••• អ្នកនឹងរកឃើញតុល្យភាពក្នុងពេលដែលយើងកំពុងរស់នៅជាមនុស្សនេះ ។

ខ្ញុំសូមលើករឿងនិទានដំពេលនិយមមួយក្នុងលិទ្ធិព្រាហ្មដូចតទៅៈ

គេជំណាលថា មានមេតោមួយផើមគ្រប់ខែ ដោយឃ្លានខ្លាំងពេក វាក៏រំកិលលួនចូលទៅជិតហ្វូងចៀម ត្រៀមលប់ចាប់សត្វដែលនៅជិតនោះ។ ពេលកំពុងខាំចៀម មនុស្សក៏មកទាន់ វាភ័យណាស់ វាស្ទុះរត់លួនចោលកូនតោនៅទីនោះ។ ដោយភ័ព្វល្អកូនតោនៅរស់ ។ មនុស្សបានយកវាមកចិញ្ចឹមបណ្តើរជាមួយហ្វូងចៀម រហូតដល់កូនតោធំ ។ ដោយបរិយាកាសជុំវិញ កំណត់កូនតោចេះស៊ីស្មៅ ប្រឡែង យំដូចកូនចៀមនានា ។ វាទទួលស្គាល់ថា វាជាសត្វចៀមដែរ។ ថ្ងៃមួយមានតោធំមួយទៀតដើរមកជិតទីនោះ ក៏ទឹកឆ្ងល់ថា ហេតុអ្វីបានជាតោមួយនេះ មានដំណើររស់នៅដូចចៀមដូច្នេះ គួរចម្លែកណាស់ ។ វាក៏លបចាប់កូនតោពីហ្វូងចៀម ហើយប្រាប់ថា "ឯងជាសត្វតោ ពុំមែនចៀមទេ ។ ចូរឯងឆ្លុះមើលមុខឯងក្នុងទឹក តើមុខដូចអញឬទេ? ប្រាកដហើយ!" កូនតោឆ្លើយ "ឥឡូវចូលឯងធ្វើគ្រាប់ ស្រែកគ្រហឹមទៅមើល" កូនតោធ្វើគ្រាប់ដំបូងពិបាក ក្រោយបន្តិចមកធម្មជាតិពិតរបស់វាត្រឡប់មកវិញ សម្លេងវាក៏រំពងដូចតោធំ ទើបកូនតោជឿពិតប្រាកដ ហើយរស់នៅជាសត្វតោរហូតទៅ។

រឿងនេះមានគតិពន្យល់ថា យើងគ្រប់គ្នាជាមនុស្សនេះ បានត្រូវសណ្តំដោយសង្គមមនុស្ស Hypnotized by human society ឱ្យលុងលក់ពុំស្គាល់ធម្មជាតិពិតរបស់ខ្លួន (យើងវង្វេង ជឿជាក់ដោយភ័នច្រឡំថា ខ្លួនឯងជារូបកាយនេះ ជាអ្នកខឹងនេះ Delusion ម្ល៉ោះហើយ យើងរស់នៅជាសត្វចៀមរហូតពុំដឹងការពិតថា យើងជាតោ ដែលមានអំណាចឫទ្ធិអស្ចារ្យ។ (ពាក្យថារស់នៅជាសត្វចៀម មានន័យថារស់នៅតែក្នុងម៉េម៉ូរី រស់នៅដោយភ័នច្រឡំ ឯរស់ជាតោ មានន័យថា មនុស្សយើងទទួលដឹងថា មានកុងស្យនិសបរិសុទ្ធដែលជាធម្មជាតិពិតរបស់ខ្លួន)។ "ចូរភ្ញាក់ឡើង!" សម្លេងបុព្វបុរសស្រែកដង្ហើយពីចម្ងាយ។ ចំណុចនេះហើយការបកប្រែពាក្យ **ព្រះពុទ្ធ** មានន័យ អ្នកត្រាស់ដឹង អ្នកភ្ញាក់រលឹក អ្នកចេញផុតពីភាពវង្វេងខាងនេះឯង)។

**(3) អំពីប្រាជ្ញាមនុស្ស Intelligence or Buddhi :**

យើងទាំងអស់គ្នាបានឱ្យតម្លៃខ្ពស់ ចំពោះប្រាជ្ញាដែលប្រើប្រាស់ក្នុងកុងស្យនិសពេលដឹងខ្លួន Waking state ។ ប៉ុន្តែប្រាជ្ញានេះ នៅមានកំណត់ជូនកាលហួសសម័យផង ពីព្រោះវាឋិតនៅក្រោមអំណាចនៃម៉េម៉ូរីពីអតីតកាល ពោលគឺ ការគិតរបស់យើងផ្អែកទាំងស្រុងទៅលើការចងចាំ ការរស់នៅ ការរៀនសូត្រ ការពិសោធន៍ផ្ទាល់ ឬមានន័យម្យ៉ាងទៀត មនុស្សយើងមើលទៅពិភពលោកខាងក្រៅតាមកញ្ចក់ដំតូចចង្អៀតនៃម៉េម៉ូរីប៉ុណ្ណោះ ហើយម្យ៉ាងទៀត ប្រាជ្ញានេះរឹតតែស្អាប់បាត់រស្មី ពីព្រោះវាត្រូវលំអកពណ៌ដោយចលនា ប្រតិកម្ម និងការរំជួលចិត្ត ប្រៀបដូចជាទឹករលកគ្រាំគ្រេងពុំឱ្យយើងមើលឃើញបាតទន្លេបានឡើយ ។

កុងស្យនិសបរិសុទ្ធ ក៏ដូចជា ដី និងពន្លឺ មានចរិតប្រកបដោយសក្តានុពល ។ ដីគេអាចផលិតបានរបស់ជាច្រើនយ៉ាង ។ ពន្លឺវាអាចបញ្ចេញរូបភាពរាប់រយ ពាន់ ម៉ឺនយ៉ាង។ កុងស្យនិសបរិសុទ្ធជាឃ្លាំងប្រាជ្ញមហាសាល ប្រាជ្ញសកល បើយើងមុជទៅដល់ទីនោះ នឹងទទួលផលជាពិតប្រាកដ ។

អ្នកប្រាជ្ញក្នុងលោកជាច្រើននាក់បានរកឃើញរូបមន្តថ្មីៗ ដោយការប្រើវិធីបួងសួងព្រះ មានន័យថា ទទួលស្គាល់ថាខ្លួនអស់សមត្ថភាព ហើយប្រគល់ថ្វាយព្រះជួយបំភ្លឺ (Surrender his small mind or his ego and go beyond) ។ ឬមានន័យថា គេបញ្ឈប់ការគិតទាំងស្រុងតាមប្រាជ្ញាផ្ទាល់ ហើយទុកចន្លោះលំហរ Space ឱ្យប្រាជ្ញាសាកលហូរចូលមកដោយឯកឯង ។ សូមលោកអ្នកសាកល្បងខ្លួនឯងផ្ទាល់ នឹងឃើញការពិតពុំខានឡើយ។ តាមការហាត់សមាធិ មនុស្សអាចមានលទ្ធភាពបានទៅដល់ និងបានពិសោធន៍កុងស្យនិសបរិសុទ្ធ និងទទួលផ្លែផ្កា គិតគូរការងារបានប្រសើរ ឬរៀនសូត្រឆាប់ចេះ ខួរក្បាលដើរពេញទំហឹង។ សព្វថ្ងៃនៅសហរដ្ឋអាមេរិក មានមហាវិទ្យាល័យមួយចំនួនបានបញ្ចូលខ្លឹមសារវិធីសមាធិទៅក្នុងកម្មវិធីសិក្សា Maharishi University in USA ។

**(4) អំពីសិទ្ធិសេរីភាព Freedom :**

យើងជាមនុស្សដែលយល់ច្រឡំថា យើងមានសេរីភាព១០០% ក្នុងការគិតគូរ ។ ដូចដែលខ្ញុំអធិប្បាយក្នុងវគ្គកុងស្យនិសពេលដឹងខ្លួន Waking state តាមពិតមនុស្សយើងគ្មានសេរីភាពទេ យើងរស់នៅក្នុងឥទ្ធិពលសង្គម និងម៉េម៉ូរីរបស់ខ្លួនពីអតីតកាលទាំងស្រុង Past Conditioning memories ។ ដោយហេតុនេះហើយ បានជាគេឃើញមនុស្សមួយចំនួនធំ ទោះដឹងថា គ្រឿងញៀននាំមកនូវគ្រោះថ្នាក់ ប៉ុន្តែគេនៅតែប្រើគ្រឿងញៀន។ ទោះបីគេដឹងថា ការជក់បារីនាំឱ្យខូចសុខភាព គេនៅតែជក់ ។ ទោះបីគេដឹងថា អំពើមួយចំនួនដូចជា ការលួចប្លន់ ឃាដកម្ម ការឆបោក ជាអំពើអាក្រក់ ក៏ប៉ុន្តែគេនៅតែប្រព្រឹត្តដដែល ។ ដោយឡែកជនណាម្នាក់ដែលបានស្គាល់រស់ជាតិនៃកុងស្យនិសបរិសុទ្ធហើយ (**តទៅលេខក្រោយ**)

Voice Of Khmer-Americans
(V.O.K.A)
ទូរទស្សន៍សម្លេងខ្មែរ-អាមេរិកាំង
ចាងហ្វាង : លោក អ៊ុង រិទ្ធី និង អ្នកគ្រូ ហុង ទិត្យ វីយ៉ាដា
ពិធីក : លោក វ៉ែន វឌ្ឍនា លោក សីលាវ័ណ្ណ និង លោក ថោង ស៊ីវិន
អ្នកបច្ចេកទេស : លោក អ៊ូច ពៅ និង លោក អ៊ុន ប៊ុនណា
ហិរញ្ញិក : អ្នកគ្រូ គីម ផាន់ណា
ទូរទស្សន៍សម្លេងខ្មែរអាមេរិកាំង សូមលំអោនកាយគោរពអញ្ជើញលោក លោកស្រី និង អ្នកនាងកញ្ញា ទស្សនាកំសាន្តការផ្សាយរបស់យើងរៀងរាល់ថ្ងៃ ច័ន្ទ វេលាម៉ោង៨:០០ យប់ ដល់ ម៉ោង៩:០០យប់ កុំបីអាក់ខាន ។
បើមានការខុសឆ្គងដោយប្រការណាមួយ សូមមេត្តាខន្តីអភ័យទោស ។
យើងសូមអរគុណទុកជាមុនចំពោះការយកចិត្តទុកដាក់តាមទស្សនា និងការទិទៀនដើម្បីរកផ្លូវចំរើន ។
Address: 21 Branch Street, unite 9, Lowell, MA 01851 Phone: 978-996-6969
E-mail: voka2010@gmail.com; www.voka2010.org 978-726-1990

តមកពីទំព័រទី ០៣ **បទសម្ភាសន៍ជាមួយលោក អ៊ូ សុវណ្ណ អគ្គកុងស៊ុល...**

ដូចជារកអាហារូបករណ៍ឱ្យនិស្សិត, ទេសចរ, សិល្បៈ, វប្បធម៌, បច្ចេកទេស ។ល។ រីឯទី៣ មានតួនាទីជាតំណាងឱ្យរាជរដ្ឋាភិបាល ដូចជាបើមានការអញ្ជើញខ្មែរឱ្យចូលរួមជាកិត្តិយសក្នុងពិធីអ្វីមួយ ខ្ញុំអាចទៅជាតំណាងឱ្យរាជរដ្ឋាភិបាលតែម្តងបាន ។

**ខ្មែរប៉ុស្តិ៍** : តើមកទល់នឹងពេលនេះ ស្ថានកុងស៊ុលបើកបានប៉ុន្មានឆ្នាំហើយ?

**អ៊ូ សុវណ្ណ** : បាទ! ចាប់ពីខែ៤ ឆ្នាំ២០០៩ មកទល់ពេលនេះប្រហែលជា១ឆ្នាំកន្លះ ជិតពីរឆ្នាំហើយ ។

**ខ្មែរប៉ុស្តិ៍** : តើក្នុងរយៈពេលជិត២ឆ្នាំនេះ លោកបានបំពេញភារកិច្ចទាំងឡាយនោះអស់ហើយឬនៅ?

**អ៊ូ សុវណ្ណ** : និយាយឱ្យចំទៅយើងខ្វះបុគ្គលិក ឬថាខ្វះថវិកាដើម្បីជួយបុគ្គលិក ហើយបើខ្ញុំត្រូវធ្វើគ្រប់ភារកិច្ចទាំងនោះ ខ្ញុំត្រូវជ្រើកខ្លួនមួយឱ្យទៅជា១០ ដូច្នេះខ្ញុំត្រូវមើលដែរ តើមួយណាសំខាន់ កាលណាមិនសូវសំខាន់ខ្ញុំក៏រំលងខ្លះទៅ កិច្ចការដែលសំខាន់ដូចជាទាក់ទងនឹងទេសចរ ពាណិជ្ជកម្ម ឬប្រជុំអ្វីនៅបុស្តុនជាដើម ខ្ញុំមិនដែលខកខានទេ។

**ខ្មែរប៉ុស្តិ៍** : ខ្ញុំឃើញឈ្មោះស្ថានកុងស៊ុល ហើយបន្ថែមពាក្យកិត្តិយស តើនេះបានន័យថា រដ្ឋាភិបាលពុំបានជួយជាថវិកាទេ ឬក៏មានអ្វីផ្សេងពីនេះ?

**អ៊ូ សុវណ្ណ** :អគ្គកុងស៊ុលកិត្តិយស វាខុសគ្នាពីអគ្គកុងស៊ុលអាជីព បានន័យថា គឺជាបុគ្គលិកឯកជនដែលស្ម័គ្រចិត្តធ្វើកិច្ចការជូនរដ្ឋាភិបាលនៃប្រទេសមួយ ឬប្រទេសកំណើតរបស់ខ្លួន បើកុងស៊ុលអាជីពវិញ គឺជាអ្នកមានសញ្ញាប័ត្រត្រឹមត្រូវ គេធ្វើការនៅក្នុងក្រសួងការបរទេសតែម្តង គេចាត់បញ្ជូនពីស្រុកខ្មែរឱ្យមកបំពេញកិច្ចការងារនៅបរទេស ហើយក្រសួងការបរទេសជាអ្នកទទួលបន្ទុកលើខ្ទង់ចំណាយផ្សេងៗ ទាំងប្រាក់បៀវត្សរ៍ មានប្រាក់ឈ្នួលសម្រាប់បុគ្គលិក មានរថយន្ត មានប្រាក់ឈ្នួលផ្ទះ ឬអាគារកុងស៊ុល...។ល។ គឺគេមានថវិការបស់គេដែលធ្លាក់មកដូចជាបីខែម្តង ផ្ទុយគ្នានេះ អគ្គកុងស៊ុលកិត្តិយសឥតមានអ្វីដូចរៀបរាប់អម្បាញ់មិញនេះទេ... ដូច្នេះហើយ បើយើងចេញទិដ្ឋាការឱ្យគេ យើងត្រូវយកតម្លៃដែលកំណត់ដោយច្បាប់ ដូចជា "Tourist visa" យើងយកតម្លៃ២០ដុល្លារបន្ថែម "Fees" កំរៃដែលយើងត្រូវការសម្រាប់ថ្លៃឈ្នួលផ្ទះ ឬថ្លៃចំណាយក្នុងស្ថានកុងស៊ុលផ្សេងៗ ។

**ខ្មែរប៉ុស្តិ៍** : កំរៃនេះគឺជាប្រាក់ចំណូលសម្រាប់ជំនួសថវិការដ្ឋឬ?

**អ៊ូ សុវណ្ណ** : នេះគេហៅថាពាក់កណ្តាលស្វ័យត គឺយើងរកចំណូលជូនរដ្ឋផង ហើយយើងរកចំណូលសម្រាប់ផ្គត់ផ្គង់ខ្លួនឯងផង ដូចជាថ្លៃឈ្នួលអាគារ ថ្លៃសេវាផ្សេងៗ ថ្លៃសាំងឡាន អ៊ីនធើណេត ឬទូរស័ព្ទ... អីចឹងនៅលើតម្លៃវិសា ២០ដុល្លារ យើងធ្វើសេចក្តីរាយការណ៍ផ្ញើរជូនរដ្ឋ ហើយកំរៃបន្ថែមដូចជា ៥ដុល្លារសម្រាប់យើងឯណោះ ហើយយើងអាចយកកំរៃសម្រាប់អ្នកណាចង់បានវិសាសនេះ លឿនជាងល្បឿនធម្មតា ដូចជាយក ១០ដុល្លារអីចឹងទេ។

**ខ្មែរប៉ុស្តិ៍** : អ្នកណាជាអ្នកចុះហត្ថលេខាលើវិសាជូនភ្ញៀវ?

**អ៊ូ សុវណ្ណ** : នៅលើវិសាគ្រប់ប្រភេទ គឺអគ្គកុងស៊ុលជាអ្នកចុះហត្ថលេខា ហើយវាយត្រាជូន ដែលគេទទួលស្គាល់ជាលក្ខណៈសាកល ទាំងអាជ្ញាធរបរទេស និងអាជ្ញាធរខ្មែរ ពីព្រោះជាការងារដែលក្រសួងការបរទេសចេញបញ្ជាឱ្យធ្វើ ។

**ខ្មែរប៉ុស្តិ៍** : តើក្នុងរយៈពេល២ឆ្នាំកន្លងមកនេះពលរដ្ឋខ្មែរទទួលយកសេវាស្ថានកុងស៊ុលកិត្តិយសនេះយ៉ាងណាដែរ?

**អ៊ូ សុវណ្ណ** : ក្នុងរយៈពេល២ឆ្នាំនេះ យើងបានបំរើពលរដ្ឋបានច្រើន គឺរួមទាំងចេញទិដ្ឋាការបាន



ច្រើន ហើយលឿន ដូចជាអាចដាក់សុំទិដ្ឋាការព្រឹក ហើយល្ងាចមកយកវិញជាដើម ហើយមកទល់នឹងថ្ងៃនេះ ខ្ញុំបានចេញវិសាបាន ៧០០ហើយ តែដោយសារវិសានេះអាចប្រើបាន១០ឆ្នាំ ដូច្នេះទាល់តែ១០ឆ្នាំទៀតបានខ្ញុំជួបគាត់ម្តងទៀត ដូចជា "K" visa នេះបាន១០ឆ្នាំ... បងប្អូនដែលទើបជាប់ Citigen ថ្មីៗគាត់មកយកវិសាជាបន្តបន្ទាប់... ហើយក្រៅពីនោះអ្នកមកបន្តសុពលភាពលិខិតឆ្លងដែនខ្មែរមិនសូវមានច្រើនដូចវិសាទេ ហើយបងប្អូនយើងច្រើនផ្ញើរទៅធ្វើនៅស្ថានទូតឯវ៉ាស៊ីនតុនឌីស៊ី តាមសំបុត្រ ហើយ១០ថ្ងៃ ឬកន្លះខែអីទើបត្រឡប់មកវិញ... បើធ្វើនៅទីនេះ ធ្វើភ្លាមបានភ្លាម ហើយមិនភ័យបាត់បង់តាមការផ្ញើរអ្វីទេ ។

**ខ្មែរប៉ុស្តិ៍** : តើជាទូទៅបងប្អូនខ្មែរ មានដឹងថាមានស្ថានកុងស៊ុលខ្មែរ ឬមានដឹងថា អគ្គកុងស៊ុលធ្វើអ្វីខ្លះដែរឬទេ?

**អ៊ូ សុវណ្ណ** : កន្លងមកខ្ញុំតែងធ្វើការផ្សព្វផ្សាយជាញយៗ មានការចូលរួមផ្សាយក្នុងទូរទស្សន៍ជាកម្មវិធីខ្មែរ ឱ្យដឹងទៅបងប្អូនខ្មែរ ពីសេវារបស់យើងឱ្យលេខទូរស័ព្ទ ឬអាស័យដ្ឋានគ្រប់យ៉ាងដែរ ។

**ខ្មែរប៉ុស្តិ៍** : នៅទីនេះខ្ញុំឮការទិនានថា "ស្ថានកុងស៊ុល" ជាចលនារបស់គណបក្សប្រជាជន តើពាក្យថាចលនារបស់គណបក្សមានធ្វើឱ្យគេស្អប់ ឬរំខានដល់ការប្រើសេវារបស់ស្ថានកុងស៊ុលដែរឬទេ?

**អ៊ូ សុវណ្ណ** : យើងមានការទទួលប្រតិកម្មនេះដែរកាលពីដើមដំបូង មានការនិយាយតាមអាស៊ីសេរី តាមវីអូអេ ថាស្ថានកុងស៊ុលហ្នឹងជាសេនាធិការរបស់គណបក្សប្រជាជន ប្រើមនុស្សជាគណបក្សប្រជាជន ធ្វើឱ្យមានការភ័យខ្លាច ជាពិសេសចំពោះអ្នកមាននិន្នាការប្រឆាំង តែការណ៍នេះមិនសូវជាជះឥទ្ធិពលអ្វីខ្លាំងក្លាទេ ដោយសារបងប្អូនត្រូវការគឺគាត់នៅតែមករកដោយសារគេស្គាល់ខ្ញុំ កាលខ្ញុំនៅគណបក្ស សម រង្ស៊ី ក៏ស្គាល់ មកដល់ឥឡូវនេះនៅតែស្គាល់គ្នា... រឿងនយោបាយជារឿងមួយឯរឿងសេវាកម្មជារឿងមួយទៀត។

**ខ្មែរប៉ុស្តិ៍** : តើលោក អ៊ូ សុវណ្ណ នាពេលមុនជាសមាជិកគណបក្សប្រឆាំងនឹងរដ្ឋាភិបាល ឥឡូវនេះលោកជាអគ្គកុងស៊ុលកិត្តិយសរបស់រដ្ឋាភិបាល តើតួនាទីខុសគ្នានេះ តើធ្វើឱ្យលោកបំរើបញ្ហារបស់ប្រជាពលរដ្ឋខុសគ្នាប៉ុណ្ណា?

**អ៊ូ សុវណ្ណ** : នៅទីក្រុងឡូវែលនេះ គេស្គាល់ខ្ញុំច្រើនដែរ គឺរយៈពេល៧ឆ្នាំនោះ ខ្ញុំបានធ្វើពលិកម្មច្រើនចំពោះគណបក្ស សម រង្ស៊ី គេក៏ដឹងដែរថា តើខ្ញុំឈ្មុសឈ្មុលប៉ុណ្ណា? ដើម្បីពង្រឹង ចងក្រងជាសាខាជាថ្នាក់ដឹកនាំ នៅពេលគណៈប្រតិភូមកម្តងៗ... ឥឡូវដែលខ្ញុំត្រឡប់ទៅចូលគណបក្សប្រជាជន គឺឥតមានអ្វីខុសប្លែកទេ គឺនិយាយថាខ្ញុំស្នេហាជាតិ គឺខ្ញុំជួយជាតិតាមការបញ្ចេញមតិកាលពីខ្ញុំនៅជាមួយគណបក្ស សម រង្ស៊ី ដូចជា ខ្ញុំក៏ធ្លាប់ធ្វើសារព័ត៌មានគឺចាប់ផ្តើមដំបូងឡើយពីកម្ពុជាពុំទាន់មានសេរីភាពសារព័ត៌មាន យើងធ្លាប់ដើរកាត់ព្យុះភ្លៀង រហូតដល់កាត់ឧបសគ្គធំៗ ជួនកាលស្ទើរបាត់បង់ជីវិតក៏មាន... ឥឡូវនេះប្រជាជនលោកចេះប្រើវិស័យសារព័ត៌មាន ទោះជានៅជនបទក៏គាត់រកកន្លែងបញ្ចេញមតិបាន ដោយមិនចាំបាច់ខ្ញុំ មិនចាំបាច់សារព័ត៌មានណា គឺអាចធ្វើដោយខ្លួនឯងបាន ។ ខ្ញុំយល់ទេ ពេលនេះជាឱកាសដែលខ្ញុំអាចងាកមកជួយរដ្ឋាភិបាលម្តង ព្រោះថាទាំងរដ្ឋាភិបាល ទាំងបក្សប្រឆាំងមានគោលដៅដូចគ្នា ជួយកសាង ដឹកនាំ រៀបចំជាតិ គឺយើងដើរវាខុសគ្នា រីឯគោលដៅវាដូចគ្នា... ដូច្នេះខ្ញុំគិតថា គណបក្សប្រជាជនពុំមែនជាគណបក្សមួយខ្ជិខ្ជា, ខ្វះធនធាន ឬជាគណបក្សមួយមិនល្អសម្រាប់ជាតិ ដូចដែលយើងធ្លាក់គិតមកនោះទេ... គឺថាយ៉ាងហោចណាស់ គឺយើងទាំងអស់គ្នាដឹងថាថ្ងៃនេះយើងអាចរស់បានក្នុងសុខសន្តិភាព មិនដូចកាលពី៣០ឆ្នាំមុននោះទេ វាខុសគ្នាមេឃនិងដី ដូច្នេះហើយបានជាខ្ញុំសម្រេចថា មកជួយកិច្ចការងារផ្ទាល់ជាមួយរាជរដ្ឋាភិបាល ប៉ុន្តែឱ្យខ្ញុំក្បត់ឧត្តមគតិខ្ញុំ គឺខ្ញុំឥតក្បត់ទេ ពីមុនខ្ញុំតស៊ូដោយមតិ ឥឡូវខ្ញុំធ្វើផ្ទាល់ដៃបំរើប្រជារាស្ត្រ បំរើជាតិជាមួយរាជរដ្ឋាភិបាល ដែលមានសម្តេចតេជោជាអ្នកដឹកនាំ ។

**ខ្មែរប៉ុស្តិ៍** : សុំអរគុណលោក អ៊ូ សុវណ្ណ ចំពោះបទសម្ភាសន៍នេះ ៕





ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ
សេវាលិខិតឆ្លងដែន
សេវាអន្តោប្រវេសន៍
កក់សណ្ឋាគារ ឬជួលឡាន

**USA**
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
angkortravelphilly@yahoo.com

**Cambodia Office: Victory Travel (Skin Belle)**
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.

SERVING SINGAPOR, EVA AIR, CHINA , ASIANA KOREAN AIRLINES,

**New World Travel II**

ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថេ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬ ជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។

**Services**
Rush Re-Entry Permit
Reserve Cruise,
Hotels and Car Rentals
Domestic & International flights

600 Washington Ave Suite #8 / Philadelphia, Pa 19147
Tel: (215) 463-1257 / Fax: (215) 463-2036

# NEW GOLDEN PALACE

**SEAFOOD RESTAURANT**
**801-21 Washington Avenue.**
**Philadelphia, Pa 19147**

**Tel: 215-627-2822**

Business Hours: Monday–Sunday. 10 a.m.–10 p.m.

## សូមអញ្ជើញគ្រោងពិធីរបស់លោកអ្នកជាមួយនឹងយើងខ្ញុំ

*Plan your next event here!*

- *Wedding Reception* • ពិធីមង្គលការ
- *Birthday Parties* • បុណ្យខួបកំណើត
- *Business Meetings* • ប្រជុំការងារជំនួញ
- *Private Parties* • ពិធីជប់លៀងឯកជន
- *Fundraisers* • បុណ្យរៃអង្គាសប្រាក់
- *We Accept Reservation for Holidays* • យើងទទួលខ្ទប់កក់កន្លែងធ្វើពិធីនៅថ្ងៃឈប់បុណ្យទានបាន



យើងបំរើម្ហូប ឌិម ស៊ុម រាល់ថ្ងៃ ពីព្រឹកដល់ល្ងាច



**We Serve Dim Sum Daily All Day Long &**
**Also Try Our Vietnamese Phở**



កុំភ្លេច ភ្លក់ "ហ្វើ" វៀតណាមរបស់យើង

**From 10 a.m. – 10 p.m.**

## ពិធីជប់លៀងល្ងាចពិសេស ជាមួយក្រុមគ្រួសារ

### ROYAL FAMILY DINNER PACKAGE



**សំរាប់៦នាក់-ម្ហូប៧មុខ- $78**
**DINNER FOR 6 - 7 Entrées $78**

1. Vietnamese Spring Roll
2. Sweet Sour Pork Chops
3. Seafood Bean Curd Soup
4. Lobster with Ginger & Scallion
5. Steam Fish
6. House Special Fried Rice
7. Seasonal Fruit

**សំរាប់៨នាក់-ម្ហូប៨មុខ- $98**
**DINNER 8 – 8 Entrées $98**

1. Palace Appetizer
2. Shrimp Hot & Sour Soup
3. Baby Claims with Black Bean Sauce
4. Sautéed seafood with Chinese Vegetables
5. Lobster with Ginger & Scallion
6. Steam Fish
7. House Special Lo Mein
8. Seasonal Fruit

**សំរាប់១០នាក់-ម្ហូប៩មុខ- $128**
**DINNER 10 – 9 Entrées $128**

1. Fried Shrimp Rolls
2. Salt Baked Shrimp
3. Seafood with Sweet Corn Soup
4. Seafood Bird's Nest
5. Crispy Fried Chicken
6. Double Lobsters with Ginger Scallion
7. Steam/Fried Fish Tilapia
8. House Special Fried Rice
9. Seasonal Fruit



ឥឡូវនេះអ្នកអាចញញឹមបានហើយ!








## ពេទ្យថែរក្សាធ្មេញប្រចាំគ្រួសារ

# FAMILY DENTAL CARE
AT
## SMILE CARE CENTER
626 Snyder Avenue. Philadelphia, Pa 19148

យើងខ្ញុំអាចបកប្រែភាសាខ្មែរជូនលោកអ្នក សូមទាក់ទងជាមួយ ឈ្មោះ រិន ហេង និងដា លែនតាវ ដើម្បីណាត់ពិនិត្យ

**WE SPEAK CAMBODIAN. PLEASE CONTACT :**
**MALY CHHORN 215-391-4100**

**Children and Adults Welcome**

- Exams
- Root Canals
- Extractions
- Cleanings
- Braces
- Dental Implants

**We accept all types of insurance including Medicare & Medicaid**

**PLEASE CALL TO MAKE YOUR APPOINTMENT TODAY !**

**(215) 391-4100**

យើងទទួលយកគ្រប់ប្រភេទ អ៊ិនស្វ៊ិន ដោយរាប់ទាំងមេឌីឃែ និងមេឌីឃេដ ផង សូមទូរស័ព្ទមកយើងខ្ញុំ នៅថ្ងៃនេះ ដើម្បីណាត់ពិនិត្យនូវលេខ ***(215) 391-4100***

តមកពីទំព័រទី ០១ **វត្តពីរឈ្មោះតែមួយ ត្រែរតនារាម...**

អីចឹងបានតែថា អាមួយម៉ោ អាមួយឥតម៉ោ ( អីចឹងលោកឥតពេញចិត្តទាំងសងខាង) ថាអីចឹងក៏បានដែរ បើយើងឥត ត្រូវការអ្នកឈ្លោះគ្នា មែនណាំ !

អ្នកស្រីឡាយ : "វត្តរុងរឿង សង្គមខ្មែរសុខសាន្ត" បានន័យថា ប្រជាជនសប្បាយចិត្ត ។ មកធ្វើបាតកម្មថ្ងៃនេះ ចង់ឱ្យវត្តផ្សះផ្សាគ្នា ដោយឥតមានលោកណាមួយត្រូវចេញពីវត្តទេ ហេតុដែលវត្តលើ និងក្រោម មិនព្រមផ្សះផ្សាគ្នា មកពីអ្នកដឹកនាំរឿងដែលថាតុលាការហៅឱ្យជ្រើសរើសតំណាងមកម្ខាងម្នាក់ មកជួបគ្នាអីនោះ ខ្ញុំឥតមានដឹងទេ ខ្ញុំអ្នកល្ងង់ខ្លៅចង់ឱ្យវត្តនៅឈប់ឈ្លោះគ្នាទៅ ខ្ញុំថាអ្នកទាំងពីរខាងសុខទាំងអស់គ្នា ។



លោក សារី : វត្តជាទីសក្ការៈទូទៅទាំងអស់គ្នា មិនមែនជាទីឯកជនទេ ប្រហែលជាមានអ្នកយកវត្តនេះធ្វើជាទីឯកជនហើយ បានជាមានការប្តឹងផ្តល់គ្នាបួនដប់ឆ្នាំហើយមិនឈប់សោះនោះ ខ្ញុំឥតមានកាន់ខាងវត្តណាមួយទេ តែដល់ខ្ញុំមកវត្តឃើញលោកតា សៅ ឃន នេះធ្វើសមាធិអីត្រឹមត្រូវ ខ្ញុំក៏នៅទីហ្នឹងទៅនៅខាងលើ តែឥតកាន់ជើងខាងណាទេ ឱ្យតែចេះស្រឡាញ់គ្នា ចេះសាមគ្គីគ្នា ខ្ញុំសប្បាយចិត្តហើយ... ខ្ញុំឮថាប្តឹងគ្នាបណ្តេញលោកចេញពីវត្តអ្នកដែលឮពាក្យអីចឹងៗទេ?



អ្នកស្រី ទីម នួន : វត្តហ្នឹងបែកបាក់គ្នា មានលើ មានក្រោម គេប្តឹងគ្នាអស់រយៈ១០ថ្ងៃហើយ ខ្ញុំចង់ឱ្យមានការបង្រួបបង្រួម កុំឱ្យមានប្តឹងផ្តល់ពីរឿងសាសនា ហើយកសាងសាសនាតែមួយ ខ្ញុំឥតកាន់វត្តណាទេ សុំឱ្យតែរួបរួមខ្មែរហើយនឹងសាសនាខ្មែរ ចំពោះការគ្រប់គ្រងវត្ត បើតាមខ្ញុំដឹងមកមុននឹងកើតវត្តត្រូវតែមានព្រះសង្ឃ ដល់បញ្ចុះសីមាហើយ ព្រះសង្ឃគ្រប់គ្រងតាមច្បាប់ គណកម្មាការគឺនៅពី ក្រោយលោកកន្លងមកហើយ គឺមានតែព្រះសង្ឃទេ ដែលជាអ្នកដឹកនាំសង្គមខ្មែរ និងវត្តទូទៅហ្នឹង ។



លោក សារុន ទិត : វត្តប្តឹងគ្នា ពីព្រោះមានមនុស្សលោភមានគិតប្រយោជន៍... អ្នកដែលលោភហ្នឹងអាចខុសទាំងពីរ តែអ្នកប្តឹងព្រះសង្ឃហ្នឹង ប្តឹងវត្ត ប្តឹងអីហ្នឹង បានធ្វើឱ្យសង្គមបែកបាក់បានផ្តើមឡើង១០ឆ្នាំហើយមិនបាត់សោះ គេមានរៀបចំគណកម្មាការសុំសម្រុះសម្រួល គាត់ក៏មិនព្រមជួបទៀត ដើម្បីឱ្យមានសាមគ្គីភាពឡើងវិញ ទាល់តែអនុម័តដោយការបោះឆ្នោត បើមិនមានការបោះ ឆ្នោតដោយប្រជាធិបតេយ្យត្រឹមត្រូវទេ គឺមិនចប់ទេ ម្នាក់ៗយកឈ្នះតែរៀងៗខ្លួន ខ្ញុំឥតកាន់ជើងខាងណាទេ ខ្ញុំឃើញអ្នកប្តឹងចេញតែប្តឹងទៅអ្នកខាងក្រោម ចេះតែតាមទៅ តាម១០ឆ្នាំហើយ តុលាការហ្នឹង មិនថាយុត្តិធមិ ឬមិនយុត្តិធមិទេ តែឥតដឹងវប្បធម៌ខ្មែរជាក់លាក់ទេ ជឿតាមតែមេធាវី ខ្ញុំជឿថាមេធាវីហ្នឹងគាត់អូសបន្ទាយពេលវេលាសម្រាប់ផលប្រយោជន៍របស់គាត់ យើងចេះតែតាមគាត់យកលុយទៅចាយរៀងៗខ្លួនទៅខ្លះ ថាចាយរាប់ម៉ឺនខ្លះថាចាយអស់រាប់សែន ប៉ុន្តែតែខ្ញុំឥតមានឯកសារទេបាទ! ។



សំណាង ឃឿន : ចំពោះរឿងប្តឹងគ្នា វត្តលើ វត្តក្រោមនេះ ខ្ញុំមានការឈឺចាប់ណាស់ ដោយឃើញសង្គមព្រះពុទ្ធសាសនាឈ្លោះគ្នាយើងត្រូវការឱ្យមាន General Election មួយដើម្បីប្រគល់ឱ្យក្រុមណាមួយដែលឈ្នះឱ្យគេធ្វើការពីរបីឆ្នាំទៅរួចឱ្យមានការបោះឆ្នោត... គេឈ្នះបានយើងដើរចេញសិនទៅ... សុំឱ្យតុលាការហ្នឹងសម្រេច ឱ្យមានការបោះឆ្នោត ។

សវនាការនេះបានប្រព្រឹត្តទៅក្នុងរយៈពេលខ្លី ដោយមានការលើកថ្ងៃធ្វើសវនាការទៅខែ១១វិញ ហើយនឹងការតែងតាំងចៅក្រមថ្មីមួយទៀត ដើម្បីជំរះក្តីឱ្យទាន់ចិត្ត ៕



# ហាងជួសជុលឡាន អិន ខេ
# NK AUTO

Free Estimate

5901 OXFORD AVENUE. PHILADELPHIA, PA 19149
**TEL. 215-533-0163**

**ជួសជុលទូទៅនឹងសេវាកង់**
**បើមកធ្វើឡានតាមរយ:ពាណិជ្ជកម្មនេះ នឹងទទួលបានបញ្ចុះតម្លៃពិសេស**

**General Repair & Tire Services**
**Mention this AD you will receive discount:**




**Inspection $35.00**  **Oil Change $20.00**

Contact Vannak or Vanney **215-533-0163**



# DRANOFF ASSOCIATES
*Attorneys at Law*



"ដ្រាណុហ្វ អាសូស៊ីយេត (DRANOFF ASSOCIATE ) គឺជាមណ្ឌលការពារតាមផ្លូវច្បាប់ ដែលធ្វើការប្រកបដោយភក្តីភាព ដើម្បីតំណាងឱ្យអ្នករងគ្រោះ ដែលមានរបួសរូបរាងកាយ ។

ស្ទីវិន ដ្រាណុហ្វ (STEVEN DRANOFF) គឺជាមេធាវីនៅសាលាក្តីមានបទពិសោធន៍យ៉ាងខ្ពស់ខាងសេវាច្បាប់ ៣៥ឆ្នាំ ។

យើងធ្វើការដោយយកកំរៃពីការងារដែលប្រគល់ឱ្យលោកអ្នកមិនចាំបាច់ចេញថ្លៃចំណាយអ្វីមុននឹងលោកអ្នកទទួលប្រាក់សងពីមុខរបួសលោកអ្នកនោះទេ ។

ជំនួយខាងផ្លូវច្បាប់អាចផ្តល់ជូនជាភាសា ស្បាញ៉ូល ខ្មែរ វៀតណាម កូរ៉េ និង ចិន ។

- **របួសលើរាងកាយ :** គ្រោះថ្នាក់រថយន្ត, ឡានឈ្នួល "សិបតា", ឡានត្រឹក, តាក់ស៊ី, ជិះកង់, ថ្មើរជើង, រអិលដួលលើទឹកកក, លើចិញ្ចើមថ្នល់ ឬក្នុងអាគារលក់ទំនិញ, គ្រោះថ្នាក់ដោយបានទិញរបស់ខូចមកប្រើ ឬកំឆ្កែខាំ... ។
- **ការប្រហែសក្នុងវិជ្ជាជីវ: និងសិទ្ធិរបស់អតិថិជន :** ព្យាបាលតាមវិជ្ជាពេទ្យពុំបានត្រឹមត្រូវ, មរណភាពឥតសមហេតុផល, រាយមាយក្នុងការថែទាំមនុស្ស... ។

**DRANOFF ASSOCIATES**

121 South Broad Street, Suit 1210, Philadelphia, PA 19107
215-732-3333 (phone) 215-732-8059 (fax)
sdranoff@dranofflaw.com



ឥតយកថ្លៃ លើ វីតាមីន
ឥតយកថ្លៃ លើ ថ្នាំចាក់ ឬលេបបង្កាជម្ងឺ
ឥតយកថ្លៃលើ យកវេជ្ជបញ្ជាទៅទិញថ្នាំ និងបញ្ជូនថ្នាំមកវិញដល់ផ្ទះ

# Rx EZ PHARMACY

**INTRODUCING THE MOST COST EFFECTIVE PLAN FOR SELECTED GENERIC DRUGS**

| $3.99 | $12.99 |
|---|---|
| ថ្នាំសម្រាប់ប្រើ30ថ្ងៃ | ថ្នាំសម្រាប់ប្រើ90ថ្ងៃ |

**215-728-6300**

**Bela M. Patel**
Pharmacist

Hours: M-F 9-7, Sat 10-3, Sun Closed
1701 Cottman Ave. Philadelphia, PA 19111



# Nationwide

Insurance & Financial Service

**សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ**

We offer Cheap Price for Every Client

**យើងធ្វើជូនគ្រប់គ្នៀវដោយតម្លៃថោក**

| | |
|---|---|
| Business Liability Insurance | [illegible] |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រងសុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

**Discount 30% when you purchase Home & Auto Insurance**
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ ធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8 Philadelphia, PA 19147
Tel: (215) 463-1257 , Fax: (215) 463-2036

# HONG KONG Super Market

FAMER'S BEST

Newly Renovated. Added new section .

Clean and Improved management !

ទើបនឹងកែលំអរថ្មីឡើងវិញ

-បន្ថែមផ្នែកលក់ថ្មីទៀត ហាងស្អាត ហើយបង្កើនគុណភាពគ្រប់គ្រង

**Weekly Sale** លក់ចុះថ្លៃរៀងរាល់សប្តាហ៍

## HONG KONG SUPERMARKET (PA) WEEKLY PROMOTION ITEMS

## ON SALE PERIOD 9/24/10-9/30/10



4/$5



$0.99 per lb



$099 per lb




$4.99 per box



$0.69 per Can




$3.99 per Bag



3/$10



3/$1.99



$4.89 per lb



$1.99 per BLT



$1.29 per BLT




4/$3




3/$10



$ 0.69 per lb



$0.69 per lb



$0.99 per lb

571 ADAMS AVE.PHILADELPHIA, PA 19120 Tel : 215-7281300 Fax : 215-728-1600

- ចំណាយ $140 ដុល្លារ ទទួលបានអង្ករស្រូវស 25 ផោន
- ចំណាយ $100 ដុល្លារ ទទួលបានខ្ទះកេសជ្ជៈ ឬទឹកញ៉ូប់មួយប្រអប់ ( តម្លៃ 8.99 )
- ចំណាយ $25 ដុល្លារ ទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។

OPEN 7DAY 8:00-9:00

អបអរសាទរវប្បធម៌កម្ពុជា
A celebration of Cambodian culture

សិល្បៈខ្មែរ
មហាវិទ្យាល័យ Bryn Mawr
ថ្ងៃទី ២៦ ខែ កញ្ញា ដល់
ថ្ងៃទី ២៣ ខែតុលា



# Khmer Arts at Bryn Mawr College

September 26 ~ October 23

ក្រុមសិល្បៈខ្មែរចំនួន ២០នាក់មកពីភ្នំពេញរួមមានអ្នករាំ និងអ្នកភ្លេង ធ្វើការសម្តែងស្នាដៃថ្មីរបស់លោកស្រី សុភីលីន ជាម សាភីរ៉ូ រឿង ជីវិតអសុរា នៅសាល Goodhart, Bryn Mawr នៅថ្ងៃសុក្រ ទី ២២ ខែ តុលា ម៉ោង ៨ យប់ តម្លៃសំបុត្រ: $២០/១៨. និស្សិត $១០. ក្មេងក្រោម១២ឆ្នាំ $៥



Friday, October 22, 8 PM
Goodhart Hall, Bryn Mawr
KHMER ARTS ENSEMBLE
Twenty dancers and musicians from Phnom Penh perform Sophiline Cheam Shapiro's newest work, *The Lives of Giants.*
Tickets: $20/18, student tickets --$10. children under 12--$5
To purchase tickets go to http://www.brynmawr.edu/arts

Dance Advance

កម្មវិធីសិល្បៈខ្មែរផ្សេងៗនៅ
មហាវិទ្យាល័យ BRYN MAWR
ក្រុមសិល្បៈខ្មែរ. រឿង ជីវិតអសុរា
១០-២២ គឺជាកម្មវិធីលក់សំបុត្រ។ កម្មវិធីឯទៀតៗ ចូលរួមដោយសេរី។ សូមទូរស័ព្ទកក់កន្លែងតាមរយៈ លេខ ៦១០-៥៦២-៥២១០

៩-២៦ ការសម្តែង ការរកឃើញរបាំខ្មែរ ចំរើន យិន នៅរោងល្ខោន Hepburn ក្នុងសាល Goodhart

៩-២៨ របាំងមុខ និងសំលៀកបំពាក់របាំបុរាណខ្មែរ ចំរើន យិន នៅបន្ទប់តន្ត្រី Goodhart

១០-១៨ សិក្ខាសាលា របាំស្វាខ្មែរ-ថាវរ៉ូ ភីម នៅ Pem Dance Studio

១០-២៣ វគ្គបង្ហាត់បង្ហាញភ្លេងបុរាណខ្មែរដោយ ក្រុមសិល្បៈខ្មែរ នៅសាល Goodhart

បាឋកថា និងការបង្ហាត់បង្ហាញពីក្រុមសិល្បៈខ្មែររបស់

១០-២០ និស្សិតមហាវិទ្យាល័យ Swarthmore នៅកន្លែងហាត់រាំ

១០-២១ និស្សិតមហាវិទ្យាល័យ Bryn Mawr នៅកន្លែងហាត់រាំ ម៉ោង ៤ រសៀល

១០-២៣ សមាគមខ្មែរភាគខាងជើង នៅកន្លែងហាត់រាំ ម៉ោង ១០:៣០ ព្រឹក ( សំរាប់និស្សិតក្មេងៗ)

១០-២៣ ការសម្តែង នៅ Philadelphia ម៉ោង ១:០០ រសៀល

មានការបញ្ចាំងខ្សែភាពយន្ត និងកម្មវិធីផ្សេងៗទៀត។ សំរាប់ពត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ
http://www.brynmawr.edu/arts

MORE KHMER ARTS EVENTS /
BRYN MAWR COLLEGE
Khmer Arts Ensemble *The Lives of Giants,* 10/22 is a ticketed event. All other events are free. Call to reserve space, 610-562-5210.

9/28 7:00 PM — Performance: A Thousand Years in the Making: Cambodian Royal Court Dance, Chamroeun Yin, Hepburn Theatre, Goodhart Hall

9/28 6:30 PM — Created by Hand: Cambodian Royal Court costumes and masks ~ with Chamroeun Yin, Goodhart Music Room

10/4 4:00 PM — Dancing Through Death: The Monkey, Magic and Madness of Cambodia - Film showing and discussion with Thavro Phim

10/18 7:00 PM — Workshop: The Cambodian Monkey Dance - Thavro Phim, Pem Dance Studio

10/23 7:00 PM — Lecture/Demonstration on Cambodian music with Khmer Arts Ensemble, Goodhart Hall

Master classes with Khmer Arts Ensemble

10/20 4:30 PM — Swarthmore College, Dance Studio

10/21 4:00 PM — Bryn Mawr College, Dance Studio, 4:00 PM

10/23 10:30 AM — Cambodian Association North Center, Dance Studio, 10:30 AM (suitable for younger students)

10/23 1:00 PM — Performance Garage, Philadelphia, 1:00 PM

Plus other events.
Go to http://www.brynmawr.edu/arts for more information.

The Khmer Arts Ensemble residency and Cambodian Arts events are made possible by a grant from the Pew Center for Arts & Heritage through Dance Advance



# ផ្ទះបីកន្លែងដែលទើប ជួសជុលហើយថ្មីស្រឡាង





-នៅទីប្រជុំជន ដែលសម្បូរណ៍ដោយអ្នកត្រូវការផ្ទះឈ្នួល
-តម្លៃថោកជាងតម្លៃទីផ្សារ តម្លៃ ៥.៩ ម៉ឺន ឬអ្នកឱ្យថ្លៃខ្ពស់ជាងគេ
-អាចចូលនៅបានភ្លាម បើជួលបានតម្លៃល្អ
ផ្ទះនីមួយៗមានបីបន្ទប់ដេក-ជាន់កណ្តាលមានផ្ទះបាយ បន្ទប់ទទួលភ្ញៀវ ធំទូលាយជាន់ក្រោមដីមានទឹកក្តៅ និងម៉ាស៊ីនផ្តល់កំដៅសំរាប់ខែរងា

1-2137 MARTSTON STREET | 2-2062 S. CECIL STREET | 3-1716S. RINGGOLD STREET

សូមទូរស័ព្ទរក (215) 481-0789 ដើម្បីមើលផ្ទះ



# ANGKOR AUTO SERVICE,INC.

## ហាងជួសជុលរថយន្ត "អង្គរ"

*Body Kit and Custom Paint*

ជំនាញខាងជួសជុលតួរថយន្ត និង បាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់ អិនសួរិន បានផង យើងផ្តល់សេវាគ្រប់យ៉ាង :

- State inspec tion
- Repairs Auto Glass
- Auto Frame Repairs
- Custom Painting
- Auto A/C



4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425

# COMPUTER+ L.L.C

*SURVEILLANCE SYSTEM, COMPUTER RETAILER, REPAIR & SERVICES*

**ជំនាញការខាងជួសជុលកុំព្យូទ័រ លក់គ្រឿងកុំព្យូទ័រ**
**និងដាក់គ្រឿងថតវីដេអូសំរាប់ការពារសន្តិសុខ**

REMOTE VIEWING

Remote Monitoring, Recording, Controlling through Internet from *anywhere* at *anytime*




5709 N. 5th St., Phila, PA 19120 Open: *Mon-Sat; 10am—6:00pm*
*Peter Hong Ching* * Tel: (215) 276-7000 * Fax: (215) 276-7001
E-mail: peterchng_99@yahoo.com www.computerplusllc.com

# ក្រុមហ៊ុន ទេសចរណ៍

## CENTURY TRAVEL & SERVICE CENTER

**904 South 8th Street. Philadelphia, PA 19147**
**Tel : 215-625-2889; Fax : 215-625-9395**
**Cell : 267-934-9888; Email : centuryphl@yahoo.com**

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុងនិងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

- Serve all Airlines
- Domestic & Intl. flights
- Tour Arrangements
- Passport Extension
- Khmer Laissez- Passer
- Immigration
- Tourist Visa
- Notary Public

**OFFICE Hours :**
**Mon - Sat 10:00 A.M - 6:00 P.M**
**Sun : 12:00 P.M - 5:00 P.M**

We Speak Khmer, Chinese, Vietnamese
យើងនិយាយភាសាខ្មែរ_ភាសាចិន_វៀតណាម



# ហាងខ្មែរជួសជុលរថយន្ត

**បើចង់ឲ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ**

# Rathe's Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកិរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

FREE Shipping with Your online Order

# Fantasy Printing Co., LLC.

1243 Vine Street (13th & Vine St) - Philadelphia, PA 19107
**Tel. 215-569-3744 • Fax. 215-569-3788**
email: Fantasyprinting@comcast.net
**Open Mon.-Fri. 10-6 • Sat. & Sun by Appt.**

view sample and order online at
www.FantasyPrintingLLC.com

**Print, Design & Typeset in English, Cambodian, Chinese, Vietnamese, Korean & Japanese**

- Business Cards
- Restaurant Menu
- Wedding Invitations
- Envelopes / Tickets
- Brochures / Flyers / Envelopes
- Calendars
- Invoices / Gift Certificates
- Banners / Posters
- Signage

បោះពុម្ព-គ្រោងគំរូ-និងផ្តិតអក្សរភាសាអង់គ្លេស ខ្មែរ ចិន វៀតណាម កូរ៉េ និងជប៉ុន

- ប័ណ្ណអស័យដ្ឋាន
- តារាងម្ហូបភោជនីយដ្ឋាន
- ប័ណ្ណអញ្ជើញមង្គលការ
- ស្រោមសំបុត្រ/ប័ណ្ណលក់សំបុត្រ
- លិខិតបត់ជាសៀវភៅ/ខិតប័ណ្ណលាត
- ប្រក្រតិទិន
- ប័ណ្ណទាប្រាក់គណនេយ្យ/ប័ណ្ណឱ្យរង្វាន់
- ផ្ទាំងបដារ/ ផ្ទាំងរូបខ្នាតធំ
- ផ្លាយដាក់មុខហាង

"គុណភាពខ្ពស់តម្លៃសមរម្យ"

**"Superior Quality at Affordable Prices"**

| | | |
|---|---|---|
| 50% OFF **1000 Full Color Business Cards** only **$47.50** reg. $95.00 (FREE SHIPPING) on 14-16 pt coated stock with / without UV coating expires 11/30/2010 | **20% OFF WEDDING INVITATIONS** View & order online at www.fantasyprintingLLC.com expires 11/30/2010 | **5000 Full Color Post Cards** (4x6, 2 side Full Color) only **$250** (FREE SHIPPING) expires 11/30/2010 |

# លោក កឹម សុខា ក្នុងសម្មាធិ

ដោយ : ពិន សំខុន



•••ប្រធានគណបក្សសិទ្ធិមនុស្ស គឺលោក កឹម សុខា បានអញ្ជើញទៅពិសោធន៍បច្ចេកទេសសម្មាធិរបស់ព្រះពុទ្ធសមណគោត្តម ជាលើកដំបូងនៃ "ស្ពេលប៊ើន" រដ្ឋម៉ាសាឈូសែត កាលពីថ្ងៃទី១១ សីហា ដល់២១ សីហា ឆ្នាំ២០១០។ លោកបានផ្តល់បទសម្ភាសន៍ដល់ខ្មែរប៉ុស្តិ៍ បន្ទាប់ពីអង្គុយធម៌បានចំនួន១០ថ្ងៃ នៅហ្វីឡាដែលហ្វៀ ដែលជាទីស្នាក់ការសំខាន់ជាងគេសម្រាប់ក្រៅប្រទេសរបស់គណបក្សលោក ដែល មានអត្ថន័យដូចតទៅ :

**ពិន សំខុន :** លោកអង្គុយធម៌វិប្បសនាចប់សព្វគ្រប់១អាទិត្យហើយ តើលោកមានអារម្មណ៍យ៉ាងណា?

**កឹម សុខា :** សម្រាប់ខ្ញុំជាប្រធានគណបក្សនយោបាយ ជាបុគ្គលសាធារណ ខ្ញុំដឹងហើយថាខ្ញុំមានបញ្ហាច្រើនណាស់ ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ដូច្នេះខ្ញុំយល់ឃើញថា វិប្បសនានេះនឹងជួយច្រើនណាស់ ទាំងផ្លូវកាយ ក៏ដូចជាផ្លូវចិត្តដោយជួយទប់ស្កាត់នូវការរំញោយនៃហេតុការណ៍ទាំងឡាយនេះទី១ -ទី២ កាលណាយើងតាំងចិត្តយើងឱ្យបរិសុទ្ធឱ្យហ្នឹង គឺមិនត្រឹមតែជួយខ្លួនឯងនោះទេ គឺជួយដល់អ្នកដទៃថែមទៀត ដើម្បីឱ្យទទួលបាននូវសន្តិភាពទាំងផ្លូវកាយ និងផ្លូវចិត្តពីព្រោះវិប្បសនានេះ គឺជាក្បួនខ្នាតរបស់ព្រះសម្មាសម្ពុទ្ធ ព្រះសមណគោត្តម ដែលព្រះអង្គបានធ្វើការពិសោធន៍ ដើម្បីរំដោះទុក្ខដោយសារលោកមើលឃើញថា អ្វីៗទាំងអស់ដែលកើតឡើងក្នុងលោក គឺមិនទៀង គឺអនិច្ចា នេះគឺជាក្បួនច្បាប់ធម្មជាតិ ដែលកើតឡើងហើយតែងតែមានទុក្ខ ហើយបាត់បង់ទៅវិញទាំងអស់ ហេតុដូច្នេះហើយបានជាព្រះអង្គស្វែងរកផ្លូវដើម្បីរំលត់ទុក្ខ ហើយផ្លូវមួយដែលព្រះអង្គតែងណែនាំ គឺផ្លូវសីលសម្មាធិ និងបញ្ញាដែលជាមាគ៌ានៃការរំលត់ទុក្ខ ។ ទុក្ខទាំងឡាយដែលកើតឡើងលើរូបរាងកាយ ឬក្នុងរូបរាងកាយក្តីសុទ្ធតែមកពីចិត្តទាំងអស់ ដូចជាយើងមើលឃើញអ្វីដែលគួរឱ្យស្រឡាញ់ ចាប់ចិត្ត ឬក៏កំហឹង ទោសៈ មោហៈ ឬក៏ការលប់ គឺចិត្តជាអ្នកបញ្ជាអញ្ចឹង ហើយបានជាព្រះអង្គលោកស្វែងយល់ថា បើចង់បំបាត់ទុក្ខទាំងឡាយ គឺត្រូវរំលត់ពីផ្លូវចិត្តជាមុន គឺទុក្ខទាំងឡាយកើតពីលោភៈ ទោសៈ ។ លោភៈ គឺជាការចង់បានមិនចេះឈប់ មិនឆ្អែតឆ្អន់ មិនស្កប់មិនស្កល់ ទោសៈ គឺការគុំគួន ការសងសឹក ការក្រេវក្រោធ ទាំងពីរហ្នឹង គឺជាប្រភពនៃទុក្ខដែលស្ថិតនៅក្នុងចិត្តយើងយ៉ាងជ្រៅ ហើយបើយើងចង់រំលត់វាទាល់តែកាត់ឫសគល់នៃទោសៈ មោហៈ ដែលនៅក្នុងខ្លួនយើង ។ តើយើងនឹងកាត់អ្វីមុនគេ? មានលោភៈ ទោសៈ មោហៈ គឺមានសង្ខា ព្រះពុទ្ធរកឃើញថា មានសង្ខា គឺមានទុក្ខ ហើយដើម្បីឱ្យសង្ខានោះចេញមកដើម្បីរំលត់បាន យើងត្រូវរកមើលវេទនា (Sensation) គឺយើងត្រូវបិទភ្នែក ប្រមូលដង្ហើម ប្រមូលសតិរបស់យើងពិនិត្យកន្លែងឈឺចាប់របស់យើងនៅកន្លែងណាខ្លះ ដឹងនៅកន្លែងណាហើយទុកវាឱ្យចេញមកដោយខ្លួនឯង ដោយប្រើឧបេក្ខា គឺការប្រើចិត្តជាកណ្តាល គឺការមិនត្រេកត្រអាលនឹងការស្រួលខ្លួន ឬក៏ឈឺចាប់ គឺវាអនិច្ចា តែការឈឺចាប់ក៏គង់តែបាត់ទៅវិញ បើវាស្រួលខ្លួនក៏គង់តែនឹងរលត់បាត់ទៅវិញដូចគ្នា គឺធ្វើដូចម្តេចតាំងខ្លួនឱ្យនៅឧបេក្ខា គឺឈឺចាប់ក៏មិនខ្វីភ្លើតភ្លើន ហើយបើយើងភ្លើតភ្លើននឹងវា យើងនឹងបង្កើននូវលោភៈ ចេះចង់បានកាន់តែច្រើនទៅវិញ ។ ដូច្នេះបើយើងឈឺចាប់ ហើយចេះតែខឹងនឹងវា ទោសៈ មោហៈនិងកើតឡើង ហើយព្រះពុទ្ធលោកថា ឱ្យកាន់តែចិត្តឧបេក្ខាកុំមានប្រតិកម្មនឹងការឈឺចាប់នឹងកំហឹងទាំងនោះ បើយើងប្រកាន់ចិត្តឧបេក្ខានោះបានក្នុងរយៈពេល ១០ថ្ងៃ ដែលយើងមកអង្គុយពិសោធន៍ធម៌នោះ យើងនឹងអាចកាត់បន្ថយលោភៈ ទោសៈ កំហឹង ឬឈឺចាប់បានខ្លះហើយ។ កំរិតខ្ពស់នៃវិប្បសនាគឺស្ថិតនៅលើការប្រមូលអារម្មណ៍ ប្រមូលសតិបានមូល ដើម្បីរកមើលវេទនា ហើយពេលវេទនានោះចេញមកយើងប្រកាន់យកមាគ៌ាឧបេក្ខាបាន ពេលនោះយើងកាត់បន្ថយវេទនាក្នុងខ្លួនបាន ភាពបរិសុទ្ធក៏កើតឡើងបាន។ សម្រាប់ខ្ញុំជាអ្នកនយោបាយ ជាមនុស្សសាធារណ មើលឃើញថា វាមានប្រយោជន៍ខ្លាំងណាស់ ខ្ញុំតែងតែជួបប្រទះអ្នកស្រឡាញ់ អ្នករិះគន់ អ្នកបញ្ឆោរ អ្នកបង្ខូច អ្នកវាយប្រហារយើង ហើយបើយើងចេះប្រើឧបេក្ខា ដោយមិនត្រូវត្រេកត្រអាលនឹងការស្រឡាញ់ចូលចិត្ត ឬខឹងសម្បានឹងការស្អប់ច្រណែនឈ្នានីស គឺយើងនឹងឈ្នះលើអកុសលកម្មបាន គឺបានន័យថា ចិត្តយើងអាចរំដោះទុក្ខបានហើយ ហើយបើយើងរំដោះទុក្ខបាន យើងនឹងអាចក្លាយជាអ្នកដឹកនាំម្នាក់មានចិត្តបរិសុទ្ធ ហើយបើយើងមានចិត្តបរិសុទ្ធ គឺមានសន្តិភាព យើងអាចផ្សាយមេត្តាធម៌ឱ្យដល់អ្នកដទៃបានភាពបរិសុទ្ធនឹងបានសន្តិភាពដែរ សារៈសំខាន់នេះហើយដែលខ្ញុំចង់ឃើញអ្នកនយោបាយខ្មែរ ទាំងអ្នកកាន់អំណាច ទាំងអ្នកប្រឆាំងនាំគ្នាធ្វើវិប្បសនា ដើម្បីបង្កើនសន្តិភាពសម្រាប់ខ្លួនឯង និងសម្រាប់ប្រជាពលរដ្ឋផង គឺសន្តិភាពផ្លូវចិត្តផង និងផ្លូវកាយផង ។

**ពិន សំខុន :** លោកបាននិយាយពីបច្ចេក-ទេសវិប្បសនានេះបានក្បោះក្បាយល្អណាស់ ខ្ញុំចង់ដឹងថា មុនពេលលោកអញ្ជើញទៅអង្គុយធម៌នោះ តើលោកបានដឹងពីបច្ចេកទោសនេះជាមុនដែរឬទេ?

**កឹម សុខា :** ខ្ញុំជាអ្នកស្រាវជ្រាវទ្រឹស្តីនៃព្រះពុទ្ធសាសនាពីមុនមកដែរ តែខ្ញុំពុំដែលអនុវត្តន៍ទេ ដូចជាការអត់អាហារពេលល្ងាច ការតមមិននិយាយទាក់ទងគ្នា ដូចជាការប្រមូលសតិអារម្មណ៍ឱ្យបានមូល ដើម្បីស្វែងរកវេទនានោះ ខ្ញុំមិនដែលបានសាកល្បងទេ តែខ្ញុំបានធ្វើតាមទ្រឹស្តីរបស់ព្រះពុទ្ធ ដូចជាលះបង់ពេលវេលា ទ្រព្យសម្បត្តិសម្រាប់ធ្វើការជូនជាតិ ជូនប្រជាពលរដ្ឋ លះបង់ពេលវេលានៅជិតភរិយា និងគ្រួសារ ដើម្បីធ្វើការឱ្យបានប្រសើរជូនអ្នកដទៃបានច្រើន ដែលគឺជាការពិសោធន៍ខាងក្រៅទេ ពុំមែនជាបច្ចេកទេសសម្រាប់ការកាត់បន្ថយទុក្ខនៃផ្លូវចិត្តនោះទេ ។ និយាយទៅបញ្ហាវាមានបី គឺទី១ បញ្ហាដែលកើតឡើងដោយការអានយើងរៀន យើងឮ យើងស្តាប់ ទី២ គឺបញ្ហាដែលចេញពីការវិភាគរបស់យើង រីឯបញ្ហាទី៣ គឺកើតឡើងពីការពិសោធន៍អញ្ចឹង ខ្ញុំមានបញ្ហាពីររួចហើយ ប៉ុន្តែខ្ញុំឥតមានបញ្ហាទី៣នៃការពិសោធន៍នោះទេ ។

**ពិន សំខុន :** ឥឡូវនេះលោកបានសម្រាកប្រហែលមួយអាទិត្យហើយ ហើយងាកទៅរំលឹកពីវេលាអង្គុយបទធិសោធន៍នោះវិញ តើមានអ្វីប្រែប្រួលក្នុងចិត្ត បន្ទាប់ពីអង្គុយ១០ថ្ងៃនោះដែរឬទេ? **(សូមអានបន្តនៅលេខក្រោយ)**




ភោជនីយដ្ឋានខ្មែរ
Kavei
CAMBODIAN RESTAURANT
Authentic Khmer • Thai • Lao • Vietnamese Phở
320 W OREGON AVENUE
(OREGON MARKET, SOUTH PHILLY)
215.952.6688
OPEN 7 DAYS A WEEK
9am-10pm
សម្លទំពាំងស្រស់
សម្លម្ជូរព្រៃ
សម្លម្ជូរយួន
ត្រីចៀនជូន
• ភោជនីយដ្ឋានយើងខ្ញុំ ចាប់ផ្តើមបើកពីថ្ងៃហើយ!
• មានម្ហូបខ្មែរពិសេសៗជាច្រើនមុខ ម្ហូបថៃ ឡាវ និង ហ្វៀតណាម
• មានទទួលសម្រាប់ពិធីជប់លាង ខួបកំណើត និង ពិធីផ្សេងៗ
• មានតន្ត្រីសម័យកំដររៀងរាល់ល្ងាច ថ្ងៃសុក្រ-សៅរ៍-អាទិត្យ
• លោកអ្នកអាចទូរស័ព្ទមកកក់តុទុកមុនបាន
• មានកន្លែងចតរថយន្ត ដ៏ធំទូលាយ
ញាំស្វាយខ្ចីបង្គា
អាម៉ុក
សម្លការី នំបុ័ង



# ការិយាល័យច្បាប់របស់មេធាវី អេមេត ម៉ាឌិន

LAW OFFICES OF R. EMMETT MADDEN, ESQUIRE



**ការការពារករណីឧក្រិដ្ឋ**

- បញ្ហាធ្វើតាក់
- បញ្ហាជាមួយមន្ត្រីពន្ធដារ
- បើកបរនៅពេលស្រវឹងស្រា ឬគ្រឿងញៀន
- រំលោភរូបរាងកាយ
- ចាប់ខ្លួនដោយលក់ ឬប្រើគ្រឿងញៀន
- ក្លែងបន្លំធានារ៉ាប់រង
- ការដកហូតអាជ្ញាប័ណ្ណ
- ករណីអន្តោប្រវេសន៍

**របួសលើរាងកាយ**

- គ្រោះថ្នាក់រថយន្ត
- ព្យាបាលជម្ងឺមិនត្រឹមត្រូវ
- រអិលដួល
- របួសដោយឆ្កែខាំ
- គ្រោះថ្នាក់ឡានធំ
- គ្រោះថ្នាក់កង់ម៉ូតូ
- គ្រោះថ្នាក់ផ្នែកខួរក្បាល

ពួកយើងមានបុគ្គលិកនិយាយភាសាខ្មែរ

CALL 215-884-9300

www.thephillylawers.com



Penn Asian Senior Services PASSi For a better life at home

## Penn Asian Senior Services

**Certified Nurse Assistant (CNA) Certification Classes**

**Class starts October 11th, 2010**

**Certified Nurse Aide (CNA) Program**

**Penn Asian Vocational Institute (PAVI)**

This 120 hour training program is offered evenings and weekends. The first component is classroom instruction by RN instructors at the PAVI training facility in Jenkintown. The second component is technical training held at a local nursing home. The course is conducted in English. PAVI offers the CNA program three 3 times annually. Graduates are required to pass the state exam to become a PA Certified Nurse Aide.

**កម្មវិធី Certified Nurse Aide**

កម្មវិធីហ្វឹកហ្វឺនដែលមានរយៈពេល 120 ម៉ោងនេះមាននៅពេលល្ងាច និងនៅចុងសប្តាហ៍ ហើយមានពីរផ្នែក។ ផ្នែកទីមួយគឺការបង្រៀននៅក្នុងថ្នាក់នៅកន្លែងហ្វឹកហ្វឺនរបស់ PAVI នៅ Jenkintown ដោយមានអ្នកបង្រៀនដែលជា RN ។ ផ្នែកទីពីរគឺការហ្វឹកហ្វឺនផ្នែកបច្ចេកទេសដែលធ្វើឡើងនៅ Rydal Park Nursing Home។ មុខវិជ្ជាទាំងអស់មានបង្រៀនតែជាភាសាអង់គ្លេសទេ។ PAVI មានកម្មវិធី CNA បីដងក្នុងមួយឆ្នាំ។ អ្នករៀនចប់ត្រូវប្រឡងជាប់ការប្រឡងថ្នាក់រដ្ឋដើម្បីក្លាយជា PA Certified Nurse Aide។

Requirements:
*Complete Application
*resume'
*Personal statement
*950$ tuition
*18 years and older
*High School Diploma/GED/or able to read and write at a 6th grade level
*Pass background check
*2 steps PPD or Chest X-ray
*Physically able to perform CNA

Offer in Philadelphia and Southern New Jersey Only

Call 215-572-1234 For more information visit: www.passi.us









# LCCPS

LOWELL COMMUNITY CHARTER PUBLIC SCHOOL

**206 Jackson Street • Lowell, MA 01852 • Phone (978) 323-0800 • www.lccps.org**

We believe that every child can learn and we hold high expectations for each student. Our mission promotes the celebration of each student's culture and heritage, while building a strong community that supports academic achievement in a caring and joyful environment. Hard work, focus and discipline are important aspects of our school. We offer a program that blends strong traditional academic skills within a thematic, project based curriculum. Enrichment activities and the arts are integrated into our program.

## Features of our educational program:

## យើងមានកម្មវិធីសិក្សាពិសេសៗ ដូចជា:

- **Student: Teacher ratio 12:1**
  ថ្នាក់រៀន : សិស្ស ១២ នាក់ - គ្រូ ១នាក់
- **Attention to the individual needs of students**
  ការយកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការរបស់សិស្ស
- **Extended day and year**
  ការសិក្សាមានរយៈពេលយូរ ក្នុងពេលថ្ងៃ និងឆ្នាំ
- **No tuition – we are a public school**
  បង្រៀនដោយឥតគិតថ្លៃ – យើងជាសាលារៀនរដ្ឋ
- **Instruction in Khmer and Spanish**
  មានបង្រៀនភាសាខ្មែរ និងស្ប៉ែនញ៉ុល
- **Free before and after school programs**
  កម្មវិធីបង្រៀនមុនពេល និងក្រោយពេលសិក្សា ដោយឥតគិតថ្លៃ
- **Championship sports teams**
  ក្រុមគ្រប់ប្រភេទកីឡាល្បីៗ

បច្ចុប្បន្ន សាលារៀន- ឆាទ័រកំពុងបើកទទួលសិស្ស ចាប់ពីថ្នាក់ទី ២ ៣ ៤ ៥ និង ៦ ឆ្នាំសិក្សា ២០១០ - ២០១១

LCCPS CURRENTLY HAS OPENING FOR GRADES
2,3,4, & 5 SCHOOL YEAR 2010-2011
សូមទាក់ទងមកលោកស្រី **Deborah Ye Motew** ទូរស័ព្ទ **(978) 323-0800** លេខភ្ជាប់ **115** ឬ អ៊ីមែល **dye@lccps.org**